# ព្រះពុទ្ធសាសនា និង បញ្ហាសម័យថ្មី

*និពន្ធដោយ*

*លោកបណ្ឌិត* **ជ.ភ. ម៉ាឡាឡាសេកេរ៉ា**

*ប្រែសម្រួល និងរៀបរៀងដោយ*

*ភិក្ខុ* **ស៊ុយ  សុវណ្ណ** (ធម្មបរិញ្ញាបត្រ)

*បោះពុម្ពលើកទី១*

…………………………………….

*ការផ្សាយរបស់*

**សមណនិស្សិតខ្មែរ**, *ទីក្រុងរ៉ង្គូន, សហភាពមីយ៉ាន់ម៉ា*

*សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ*

*ឧបត្ថម្ភបោះពុម្ពដោយ*

………………………………

*សម្រាប់ចែកជាធម្មទានប៉ុណ្ណោះ*

**ព.ស. ២៥៥៣**



# BUDDHISM AND PROBLEMS OF THE MODERN AGE

By

Dr.G.P Malalasekera

Translated and prepared by

Bhikkhu Suy Sovann, B.A (B.Dh)

First Edition

…………………………..

A Publication Of

Khmer Buddhist Student Monks, Yangon, Myanmar

The International Theravada Buddhist Missionary University (I.T.B.M.U)

Sponsored by

……………………………………….

For Free Distribution Only

B.E. 2553

## មាតិកាធម៌ (Contents)


អត្ថបទធម៌ ទំព័រ

សេចក្ដីផ្ដើម......................................................................៦

សេចក្ដីថ្លែងអំណរគុណ......................................................៨

ព្រះពុទ្ធសាសនា................................................................១០
Buddhism

ទេវតា..............................................................................១១
Devas

ការឧទ្ទិសបុណ្យ.................................................................១២
Transference of Merit

សទ្ធា..................................................................................១៦
Faith

សម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ..........................................................២០
Right Views and Wrong Views

សុភមង្គលនៃមនុស្សសត្វគ្រប់រូប.............................................២២
Happiness of All Beings

សាមគ្គីភាពនៃមនុស្សជាតិ...................................................២៥
Unity of Mankind

ប្រជាធិប្បតេយ្យ...................................................................២៧
Democracy

ការងារសេដ្ឋកិច្ច...................................................................២៨
Economic Welfare

កម្មសិទ្ធិលើទ្រព្យសម្បត្តិ.....................................................២៩
Ownership of Property

ព្រះពុទ្ធសាសនា និងមនុស្សជាតិ.........................................៣១
Buddhism and Mankind

សេចក្ដីបរិសុទ្ធ....................................................................៣៣
Perfection

គុណធម៌ ២ ប្រការ..............................................................៣៥
Twin Virtues

ពិភពលោកទំនើបកម្ម.........................................................៣៥
The Modern World

ពិភពលោកប្រែប្រួល............................................................២៧
The Changing World

បញ្ហាដែលមនុស្សជាតិត្រូវប្រឈម........................................៤០
Problems Facing Mankind

អតិបរមសុខ.......................................................................៤៤
Highest Happiness

មូលហេតុនៃសង្គ្រាម..........................................................៤៦
Root-causes of War

វិប្បលាសដួងចិត្ត..............................................................៤៩
Change of Heart

សាសនាពិត.......................................................................៤៩
The True Religion

បញ្ហាពិភពលោក.............................................................៥១
World Problems
អតីតកាលកំណាច..........................................................៥២
Sinister Past
ការបង្កើតអាណាចក្រ.......................................................៥៤
Secularization
ថ្នាក់វប្បធម៌..................................................................៥៦
Strata of Culture
ខន្តី និងមុទិតា................................................................៥៧
Tolerance and Sympathy
លក្ខណៈដែលលេចឡើង...................................................៦០
Salient Characteristics
អាណានិគមនិយម...........................................................៦២
Colonialism




# សេចក្តីផ្តើម

ការកើតមកជាមនុស្ស ជាការក្រណាស់ ប៉ុន្តែការកើតមកជាមនុស្សហើយ មិនបានស្តាប់សិក្សារៀនសូត្រនូវមាគ៌ាជីវិតតាមបែបសាសនាសាកល គឺ រឹងរឹតតែក្រទៅទៀត។

រឿងពិតដែលមាននៅលើលោកនេះ មិនមែនជារឿងថ្មីសម្រាប់យើងទេ តែវាថ្មីសម្រាប់បុគ្គលដែលមិនដឹង។ បញ្ហាទាំងឡាយដែលបានកើតមកចំពោះមនុស្សស្ទើរគ្រប់ដង្ហើមចេញចូល ក៏មិនជាបញ្ហារបស់បុគ្គលណាដទៃក្រៅពីខ្លួនឯង។ មនុស្សជាអ្នកទទួលខុសត្រូវខ្លួនឯង គ្មានព្រះអាទិទេពណាមកទទួលយកជំនួសយើងឡើយ។ ម៉្យាងទៀត យើងត្រូវតែធ្វើនូវបច្ចុប្បន្ននេះ អនាគតកាលជាពេលដែលមិនទាន់មកដល់ទេ រីឯអតីកាលក៏ជាពេលដែលកន្លងផុតទៅហើយដែរ មិនអាចហៅឱ្យវិលត្រឡប់មកវិញបានឡើយ។ ដូច្នេះ ពេលវេលាដ៏សមគួរបំផុតរបស់យើង គឺឥឡូវនេះឯង។

នេះជាកូនសៀវភៅដ៏តូចមួយ សម្រាប់ជួយដោះស្រាយបញ្ហាខ្លះៗរបស់មនុស្សលោកទាំងឡាយ ទោះបីជាមិនអាចបានទាំងស្រុង។ បើយើងពិតប្រាថ្នានូវសេចក្តីសុខពិត យើងមិនអាចបដិសេធចោលនូវទស្សនៈនេះឡើយ។

ដូច្នេះ សូមមេត្តាក្រឡេកមើល និងពិចារណាឡើងវិញនូវមាគ៌ានេះ វាមិនទាន់ហួសពេលទេ សម្រាប់យើងគ្រប់គ្នា។ ប៉ុន្តែការពិត វានៅត្រង់ថា យើងមិនព្រមធ្វើដឹង មិនព្រមធ្វើឮ មិនព្រមធ្វើឃើញ នូវអ្វីដែលមានពិត នៅជុំវិញខ្លួនយើងគ្រប់រូបប៉ុណ្ណោះ។ នេះជាបញ្ហាលំបាកបំផុត។

ខ្ញុំសង្ឃឹមថា សៀវភៅនេះពិតជាអាចជួយបំភ្លឺនូវមាគ៌ាឆ្ពោះទៅរកពិភពសុភមង្គលក្នុងជីវិតប្រចាំថ្ងៃពិតប្រាកដ។

សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ

ទីក្រុងយ៉ាំហ្គូន សហភាពមីយ៉ាន់ម៉ា

ភិក្ខុ ស៊ុយ សុវណ្ណ



## សេចក្ដីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព សូមសម្ដែងនូវកតញ្ញុតាធម៌ដឹងគុណ និងអរ-គុណ យ៉ាងជ្រាលជ្រៅបំផុតដល់:

- ព្រះតេជគុណ **ថន វណ្ណុខ** ប្រធានសមាគមពុទ្ធសាសនា និងអភិវឌ្ឍន៍សង្គមប្រចាំខេត្តកំពង់ចាម និងសមាជិកសមាជិកាបម្រើការទាំង-អស់ដែលបានចំណាយពេលវេលា និងកំលាំងកាយចិត្តយ៉ាងច្រើន ដើម្បីរៀបចំបោះពុម្ពសៀវភៅ “**ហេតុអ្វីបានជាមានពុទ្ធសាសនា?**” និងសៀវភៅ “**ខ្លឹមសារជីវិត**” សម្រាប់ចែកជាធម្មទានដល់បរិស័ទទូទៅ។

- លោក **យូ បាន** (Mr. Yu Ban) ពីប្រទេសម៉ាឡេស៊ី (Malay-sia) ដែលមានសទ្ធាជ្រះថ្លា ក្នុងការខ្នះខ្នែងស្វែងរកថវិកាជួយបោះពុម្ពសៀវភៅ “ហេតុអ្វីបានជាមានពុទ្ធសាសនា?” “*Why Buddhism?*” និងសៀវភៅ “ខ្លឹមសារជីវិត” “*The Purpose of Life*” សម្រាប់ចែកជាធម្មទានដល់សាធារណជន និងសូមអរគុណដល់ “មិត្តពុទ្ធសាសនិកម៉ា-ឡេស៊ី” “All Malaysian Buddhist Friends” ទាំងអស់។

- ញោមឧបាសិកា **គីម ស៊ីមឿន**, ញោមមហាឧបាសិកា **សុខ អ៊ីម**, ញោមមហាឧបាសិកា **ញ៉ឹក ប៊ុនថា**, ញោមមហាឧបាសិកា **កាំង ហ្គិចណៃ**

និងញោមញាតិទាំងក្នុងនិងក្រៅប្រទេសទាំងអស់ ដែលតែងតែជួយឧបត្ថម្ភដល់សមាគមសមណនិស្សិតខ្មែរ នៅសហភាពមីយ៉ាន់ម៉ា។

- សមណនិស្សិតខ្មែរគ្រប់ព្រះអង្គ និងញាតិញោមទាំងក្នុង និងក្រៅប្រទេសទាំងអស់ដែលបានផ្តល់ជាកំលាំងកាយចិត្តដល់ខ្ញុំ ក្នុងការងារធម្មទាននេះ។

សូមអំពើជាកុសលតាមថែរក្សាលោកអ្នកគ្រប់ពេលវេលា! អរគុណ!

សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ

ទីក្រុងយ៉ាំងហ្គូន, សហភាពមីយ៉ាន់ម៉ា



# ព្រះពុទ្ធសាសនា

## BUDDHISM

ពុទ្ធសាសនាបានកំណត់យកទីបំផុតទុក្ខ ឬព្រះនិព្វានសម្រាប់ឃុំគ្រងមនុស្សយ៉ាងពេញលេញ។ ទោះជាយ៉ាងណា ព្រះនិព្វាននេះមិនមែនមករកមនុស្ស ដូចជាវត្ថុខាងក្រៅខ្លួននោះទេ។ មនុស្សត្រូវតែស្វែងរកនូវព្រះនិព្វាននេះ។ គ្មានបុគ្គលណាមួយស្រាវជ្រាវរកឱ្យ និងព្យាបាលជំងឺរបស់ខ្លួនក្រៅពីតម្លៃបរមត្ថឡើយ។ ម្យ៉ាងទៀត ពុទ្ធសាសនាពុំមានកន្លែងណាមួយសម្រាប់ទទួលនូវអំពើបាប ដែលបុគ្គលដទៃបានធ្វើខ្លួនឯង ហើយឱ្យរួចផុតចាកទុក្ខទោសឡើយ។

Buddhism puts salvation or Nibbāna completely within the control of man. It does not, however, come to him as a gift from outside himself; it has to be won. There is no one who seeks him out and cures his alienation from ultimate values. In other words, Buddhism has no place for a Saviour who takes upon himself the sins of others and obtains for them redemption therefrom.

# ទេវតា

DEVAS

ពុទ្ធសាសនាសម្តែងពីឋាននៃពួកទេវតាទាំងឡាយ ដែលគេហៅ-ថា ទេវតា ឬជនដ៏ប្រសើរ ។ ទោះជាយ៉ាងណា ទេវតាទាំងឡាយនោះក៏មិនទៀងទាត់ ឬអមតៈដែរ ។ គេឃើញពួកទេវតាទាំងនោះក្នុងឋានផ្សេងៗ ដោយទេវតានៅឋានខ្លះ មានជីវិតវែងជាងទេវតានៅឋានផ្សេងទៀត ។ ទេវតាទាំងនោះទៀតសោត មិនមែនសុទ្ធតែមានមហិទ្ធិរិទ្ធទេ ពួកទេវតាខ្លះកើតឡើងដោយអំណាចនៃមនុស្ស ហើយសេចក្តីសប្បាយរីករាយរបស់ពួកគេ ក៏អាចបានពីមនុស្សដែរ តែមិនមែនតាមរយៈការបន់ស្រន់បួងសួង ឬការបូជាយញ្ញឡើយ ។

Buddhism admits the existence of many categories of gods who are called devas or radiant ones. None of these devas, however, is permanent and eternal. They are to be found in various planes of existence; some of them have longer life-spans than others. Though none of them is almighty, some of them are credited with superhuman powers and their favours could be won, though not by prayers or sacrifices.



ការចាប់បដិសន្ធិនៅក្នុងឋានទេវតា និងអាយុកាលរបស់ពួកគេអាស្រ័យទៅលើអំពើបុណ្យដែលពួកគេបានធ្វើកាលពីអតីតជាតិ ហើយនៅពេលកំណាប់បុណ្យនេះអស់សុពលភាព ពួកគេក៏ចុតិពីឋានទេវតានោះ ហើយមកចាប់បដិសន្ធិនៅកន្លែងណាផ្សេងទៀត ។ ភាគច្រើនជាពុទ្ធសា-សនិក ដែលពួកគេដឹងនូវអំពើល្អ ។ ពួកទេវតាទាំងអស់មិនមានសំណាងដូចមនុស្សទេ ព្រោះនៅក្នុងឋានមនុស្ស មានឱកាសសម្រាប់ធ្វើបុណ្យ-កុសល ច្រើនជាងនៅឋានទេវតា ។ មនុស្សអាចឧទ្ទិសបុណ្យកុសលដែលពួកគេបានធ្វើដល់ពួកទេវតាទៀតផង ។

Their birth in the deva world and the length of their life there depend on the good deeds they had done in previous lives and when their 'store of merit' is exhausted, they disappear from their celestial abodes and are born elsewhere. Many, if not most of them, are followers of the Buddha whose goodness they know. They are not as fortunate as human beings because in the human world there are more opportunities for good deeds than in the realm of the devas. Humans can ' transfer' to devas the merit which they attain by their good acts.

# ការឧទ្ទិសបុណ្យ

TRANSFERENCE OF MERIT

ទស្សនៈឧទ្ទិសបុណ្យកុសលនេះ គឺជាផ្នែកមួយនៃពុទ្ធវចនៈ។ ការឧទ្ទិសនេះ អ្នកម្ចាស់ទានត្រូវឧទ្ទិសកុសលដែលគាត់បានធ្វើ ដូច្នេះថា សូមឱ្យបុគ្គលដែលស្លាប់ទៅបានទទួលនូវចំណែកបុណ្យរបស់គាត់។ ការឧទ្ទិសនេះមានផលបាន នៅពេលណាបុគ្គលដែលស្លាប់ទៅរលឹកដឹងនូវអំពើល្អនេះ ហើយរីករាយត្រេកអរ។ ការរីករាយត្រេកអរនេះហៅថា "អនុមោទនា"។ អ្នកស្លាប់ទៅ អាចធ្វើការអនុមោទនាទទួលយកនូវបុណ្យកុសលនេះបាន ទោះបីជាអ្នកធ្វើនូវទាននោះមិនមានបញ្ញា។ ហេតុផលនៅត្រង់ថា នៅពេលណាបុគ្គលអនុមោទនាទទួលយកបុណ្យរបស់អ្នកដទៃ អាស្រ័យដោយមានបញ្ញា ឬមិនមានបញ្ញា ពេលនោះបុគ្គលខ្លួនឯងក៏ត្រូវសំអាតចិត្តរបស់ខ្លួនផ្ទាល់ឱ្យស្អាតបរិសុទ្ធ ហើយអំពើល្អនេះផ្តល់នូវផល ជាកុសលដោយខ្លួនឯង។ បុគ្គលដែលមានចិត្តប្រកបដោយមនសិការ និងចេតនា អាចអនុមោទនាទទួលយកនូវបុណ្យកុសលនេះបាន។ ការឧទ្ទិសកុសល គឺជាអំពើកុសលស្រាប់ ដូច្នេះ វាបន្ថែមទៅកំណប់បុណ្យដែលបុគ្គលបានធ្វើទុករួចហើយ។ ចំណែកឯ អ្នកឧទ្ទិសបុណ្យកុសលក៏មិនមានបាត់បង់អ្វីឡើយ ប៉ុន្តែគាត់កាន់តែកើនឡើងនូវកំណប់បុណ្យរបស់ខ្លួនទៀត។

The doctrine of 'transference of merit' is part of the Buddha's teaching. Such transference is made by the doer of the good deed resolving that 'so and so' may partake of the 'merit' of his good deed. The transference becomes really effective when the intended recipient becomes aware of the good deed and rejoices therein. This is called anumodanā (rejoicing therein). The anumodanā can be done even without the knowledge of the doer of the deed. The rationalization behind it is that when one finds joy in another's good deed, with or without the knowledge of the latter, one's own mind is cleansed and purified and this produces its own meritorious effects. The anumodanā can be done by anyone as a conscious, deliberate act. The 'transference of merit' is itself a good deed and, therefore, adds to the 'merit' of the good deed already done. The 'transferor' loses nothing thereby but adds to his store of merit.



គេគិតថា មានពួកទេវតាពិសេស ដែលជាអ្នកថែរក្សាការពារពុទ្ធសាសនា។ ប្រទេស អ្នកកាន់ពុទ្ធសាសនានីមួយៗ មានកន្លែងបូជាដែលជាទីមានឥទ្ធិពល ពោលគឺភូមិគ្រឹះយ៉ាងធំទូលំទូលាយ ថ្វីត្បិតតែបុគ្គលគ្រប់រូបអាចសំបូងសង្រួងបាន នៅគ្រប់ទីកន្លែងក៏ដោយ។ ភូមិទេវតាជាច្រើនកើតមកពីសាសនិកផ្សេងៗ មានដូចជា សាសនាហិណ្ឌូក្នុងករណីទឹកដីថេរវាទ។ ជាក់ស្តែង នៅក្នុងប្រទេសភូមាពុទ្ធសាសនិកទាំងឡាយ ស្វែងរកទីពឹងពីអរក្ខអ្នកតា ដែលនៅគ្រប់គ្រងលើវាសនានៃប្រជាជនភូមា។ រីឯ

នទៅក្នុងប្រទេសជប៉ុនវិញ មនុស្សគ្រប់គ្នាសង្រួងបួងសួង សូមឱ្យបានសម្រេចជាពោធិសត្វ (តួអង្គព្រះពុទ្ធ) ។

There are special devas or deities of great power, who are considered protectors of Buddhism. Each Buddhist country has its own pantheon whose sphere of influence is largely local, though there are a few who could be invoked anywhere. Many of the local deities have been borrowed or adopted from the followers of other faiths, chiefly from Hinduism in the case of Theravāda lands. In Burma, for instance, the Buddhists seek the favour of the Nats, who preside over the destinies of Burmans. In Japan, on the other hand, various Bodhisatvas (the Buddha Aspirants) are invoked.

មានកន្លែងធ្វើសក្ការបូជាផ្សេងៗ ដែលឧទ្ទិសដល់ពពួកទេវតាទាំងនេះ ជាកន្លែងទាយក-ទាយិកាទាំងឡាយ ធ្វើកិរិយាបូជាផ្លែឈើ ផ្កាឈើជានិមិត្តសញ្ញានៃការគោរពបូជា ចម្រៀងសរសើរ ឬការសូត្រមន្ត និងស្នើសុំឱ្យបានសេចក្តីសុខចម្រើន។ ពួកគេមិនបានយកសត្វធាតុបូជាយញ្ញទេ។ ទម្រង់នៃការគោរពបូជានេះ មានឥទ្ធិពលយ៉ាងខ្លាំងក្លា ដោយការប្រតិបត្តិសាសនាទេវនិយម។ ព្រះពុទ្ធទ្រង់យល់ច្បាស់ នៅពេលព្រះអង្គទ្រង់ប្រ-កាសថា ពេលណាមនុស្សទាំងឡាយ មានការខឹងសម្បារ ការតប់ប្រមល់ក្នុងចិត្ត គេតែងស្វែងរកការការពារ (ទីពឹង)។ ប៉ុន្តែសេចក្តីសប្បាយដែល



ស្នើសុំនោះ គឺទាក់ទងនឹងការងារលោកីយ៍។ ពុទ្ធសាសនិកគ្មានជំនឿថាការគោរពទេវតា អាចនាំឆ្ពោះទៅរកការចម្រើនផ្លូវចិត្តឡើយ ទោះបីជាទេវតានោះមានថាមពលប៉ុណ្ណាក៏ដោយ។

There are various shrines dedicated to these deities, where devotees make offerings of fruits and flowers as a token of homage, their praises sung or chanted and requests made for their favours. No animal is ever sacrificed. This form of worship has been greatly influenced by the practices of the theistic religions. The Buddha was quite right when he declared that in times of distress or anxiety, people are prepared to go anywhere to seek protection. But the favours asked for are concerned with mundane affairs. No Buddhist believe that the worship of devas, however powerful they are, would lead to spiritual development.

## សទ្ធា
## FAITH

ជារឿយៗគេសួរថា តើពាក្យថា "សទ្ធា" សំដៅទៅលើអ្វីនៅក្នុងព្រះពុទ្ធសាសនា? វាមានអត្ថន័យយ៉ាងប្រពៃក្នុងការទំនាក់ទំនង ដើម្បីហៅនូវពាក្យនេះ ជាភាសាបាលី ព្រោះមិនមានពាក្យណាស្មើនឹងពាក្យនេះ

ទេ ក្នុងពុទ្ធសាសនា។ មនុស្សត្រូវបានចែកទៅតាមលំដាប់ថ្នាក់ផ្សេងៗ អាស្រ័យលើកម្រិត នៃការចម្រើនអប់រំចិត្តរបស់ពួកគេ។ ដូច្នេះ យើងមាន មនុស្សសាមញ្ញធម្មតា ដែលហៅថា "បុគ្គលបុថុជ្ជន", កល្យាណ-បុថុជ្ជន, ព្រះអរិយបុគ្គល និងព្រះអរហន្តបុគ្គល។ បុគ្គលយក ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងតែងនិយាយពាក្យនេះ។ នៅក្នុង ពុទ្ធសាសនា មិនមានសកម្មភាពលាងបាបពីកំណើតទេ ទោះបីជា មាន សកម្មភាពខ្លះដែលធ្វើដោយពុទ្ធសាសនិក នៅក្នុងប្រទេសពុទ្ធសាសនិក ដើម្បីបញ្ជាក់ពីសកម្មភាព នៃការយកត្រៃសរណគមន៍ជាទីពឹងនេះ ក៏មិន មែនសុទ្ធតែមានន័យថា ពួកគេយកព្រះពុទ្ធជាគ្រូ និងអ្នកនាំផ្លូវ ព្រះធម៌ជា ទស្សនវិជ្ជា និងមាគ៌ាជីវិតរបស់ខ្លួន មួយអន្លើដោយព្រះសង្ឃជាគំរូនៃជីវិត នោះឡើយ។

The question is often asked as to what place Faith (Pāli, Saddhā) occupies in Buddhism. It may be useful in this connection to recall that in the original Pāli canonical texts, there is no word equivalent to the term 'Buddhist'. People are divided into various categories according to the degree of their spiritual development. We thus have that ordinary man, one of the 'many folk' (puthujjana), the good man (kalyāna-puthujjana), the noble man (ariya) and the perfect man (arahant). The texts do speak of people who go to the Buddha,



his Teaching the Dhamma, and his Noble Disciples (the Saṅgha) for ' refuge' (saraṇa). In Buddhism, there is no formal act or 'baptism' though there is a stereotyped formula used by Buddhists in Buddhist lands to express this act of 'taking refuge' which merely means that the devotee accepts the Buddha as his Teacher and Guide, the Doctrine as his philosophy and his Way of Life and the Saṅgha (the Community of Monks) as the exemplars of this Way of Life.

សទ្ធាក្នុងពុទ្ធសាសនាមានន័យថា ការទទួលយកនូវជំនឿ និង បញ្ញា ដែលជាការទទួលយកដ៏មានតម្លៃបំផុត។ មិនមានជំនឿផ្កាប់មុខ, មិនមានក្តីក្តាំដោយសារជំនឿ ឬត្រូវគេដាក់បណ្តាសារឡើយ។ ព្រះសម្មា-សម្ពុទ្ធទ្រង់ទទួលស្គាល់ថា មានគ្រូជាច្រើន និងមាគ៌ាជីវិតក៏មានច្រើនដែរ ដែលសម្តែងឡើងដោយពួកគ្រូទាំងនោះ ហើយសិស្សគុណនៃគ្រូប្រភេទ នេះ និងមាគ៌ាជីវិតរបស់គេក៏មានច្រើនដែរ។ បុគ្គលគ្រប់រូបមានសេរីភាព ក្នុងការជ្រើសរើសនូវជំនឿរបស់ខ្លួន មិនមានការដាក់កម្រិតណាមួយ ទៅ លើស្វ័យភាពបុគ្គលក្នុងការគោរពនេះ។ តាមពិតទៅ ព្រះសម្មាសម្ពុទ្ធមាន ការវិនិច្ឆ័យច្បាស់ណាស់ នៅពេលសាសនិកនៃគ្រូដទៃបោះបង់ចោលគ្រូ និងមាគ៌ារបស់គេ ហើយមានបំណងចង់ចូលមករកព្រះអង្គ។ ព្រះអង្គមិន បានសរសើរពួកគេឱ្យចូលមកនោះទេ ប៉ុន្តែព្រះអង្គទ្រង់ផ្តល់ឱវាទដល់ពួក

គេ ឱ្យមានការគិតបន្ថែមទៀត។ នៅពេលពួកគេនៅតែតស៊ូព្យាយាមចូលមករកព្រះអង្គទៀត ព្រះអង្គទ្រង់ឱ្យពួកគេធ្វើការសន្យាថា ពួកគេគួរគប្បីបន្តប្រសិទ្ធិពរចំពោះគ្រូដើមរបស់គេ។

The Buddhist quality of Saddhā means this acceptance in the belief and knowledge that these Refuges are worthy of such acceptance. There is no 'blind faith' involved, no case at all of 'believe or be damned'. The Buddha agreed that there were many teachers and many Ways of Life preached by them and many followers of such teachers and their Ways of Life. Everyone is lift completely free to make his choice; there is no restriction at all on the individual's autonomy in this respect. In fact, there are instances of when followers of other teachers repudiated them and wished to transfer their allegiance to the Buddha he discouraged them and asked them to give the matter further thought. When they further persisted, he made them promise that they would continue their benefactions to their earlier teachers.

ពុទ្ធដីការដ៏ល្បី ដែលទ្រង់សម្តែងក្នុងកាលមសូត្រ ជារឿយៗត្រូវបានដកស្រង់នៅក្នុងអត្ថបទនេះ គឺជាភស្តុតាងសេរីភាពនៃការជ្រើសរើសនេះ។ សូត្រនេះបានចែងយ៉ាងច្បាស់ថា គ្មានអ្វីមួយត្រូវបានទទួលយកដោយគ្រាន់អាងថា វាជាទំនៀមទម្លាប់ ឬអាជ្ញារបស់គ្រូ ឬពីព្រោះវាជា



ទស្សនៈរបស់មនុស្សយ៉ាងច្រើន, ត្រូវបានគេចែងទុកមក ឬករណីផ្សេងៗទៀត។ អ្វីៗក៏ដោយគួរគប្បីធ្វើការថ្លឹងថ្លែង ត្រួតពិនិត្យ តាមដាន និងធ្វើការវិនិច្ឆ័យថា តើវាត្រូវឬខុស ស្របតាមការត្រិះរិះឃើញរបស់ខ្លួនឬទេ។ ប្រសិនបើ ពិចារណាទៅឃើញថា ខុស ពួកគេក៏មិនគួរគប្បីបដិសេធចោលភ្លាមៗដែរ តែត្រូវធ្វើការត្រិះរិះបន្ថែមទៀត។ មិនមែនគ្រាន់តែត្រិះរិះពិចារណាដោយភាពសង្ស័យ ជាអំពើបាបដ៏អាក្រក់នោះទេ តែវាជាការជួយលើកទឹកចិត្តយ៉ាងវិជ្ជមានបំផុត។

The well-known passage in the Kālāma Sutta which is so often quoted in this context, is undisputed evidence of this freedom of choice. It states quite categorically that nothing should be accepted merely on the ground of tradition or the authority of the teacher, or because it is the view of a large number of people, distinguished or otherwise. Everything should be weighed, examined and judged whether it is true or false in the light on one's convictions. If considered wrong, they should not be rejected outright but left for further consideration. Not only is doubt nor considered a heinous sin; it is positively encouraged.

## **សម្មាទិដ្ឋិ** និង **មិច្ឆាទិដ្ឋិ**

## RIGHT VIEWS AND WRONG VIEWS

ពាក្យសម្មាទិដ្ឋិ (ការយល់ឃើញត្រូវ) និងមិច្ឆាទិដ្ឋិ (ការយល់ឃើញខុស) មិនមែនប្រកាន់តែពុទ្ធសាសនិកទេ ចំពោះរឿងនេះ។ ពាក្យនេះ ពោលសំដៅលើទស្សនៈដែលមានលក្ខណៈត្រូវ ឬខុស មិនថាប្រព្រឹត្តដោយពុទ្ធសាសនិក ឬដោយបុគ្គលដទៃណាឡើយ។ មិនមានទស្សនៈណាដែលត្រូវគេគិតថាពិសិដ្ឋក្រៃលែង ហើយមិនអាចសួរបាននោះទេ។ សេរីភាពនៃការបញ្ចេញមតិ គឺជាបញ្ហានៃសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ សូម្បីតែសុពលភាពនៃពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ក៏អាចសួរបានដែរ។ ព្រះសម្មាសម្ពុទ្ធមិនបានអះអាងដាច់ខាត ចំពោះទ្រឹស្ដីរបស់ព្រះអង្គ លើកលែងតែបទពិសោធន៍ផ្ទាល់ខ្លួនព្រះអង្គ។ អាជ្ញាពិត គឺជាអាជ្ញាដែលមានសច្ចភាពផ្ទាល់របស់ខ្លួន, សច្ចភាពដែលត្រឹមត្រូវតាមច្បាប់របស់ខ្លួន។ សច្ចភាពនេះមានថាមពលយ៉ាងខ្លាំងក្លាបំផុត ដូចជា សច្ចកិរិយាដែលបានបង្ហាញបញ្ជាក់នៅក្នុងរឿងជាតក ដែលជាផ្នែកមួយនៃមរតកវប្បធម៌របស់ព្រះពុទ្ធសាសនា។ ដូច្នេះពាក្យថា "សទ្ធា" គប្បីប្រែថា សេចក្ដីទុកចិត្ត, សេចក្ដីជឿជាក់, មានទំនុកចិត្ត ប្រសើរជាជាងប្រែថាជំនឿ, ការជឿជាក់ ព្រោះថា ពាក្យនេះមិនអាចរកឃើញនៅក្នុងទស្សនៈ "សទ្ធា" ទេ។

The terms sammādiṭṭhi (right views) and micchādiṭṭhi (wrong views) have nothing specifically Buddhist about them. They refer to views, which are



intrinsically right or wrong whether held by Buddhists or others. No view is to be considered sacrosanct and beyond question. Freedom of thought is a matter of human dignity. Even the validity of the Buddha's own statements could be questioned. The Buddha claims no authority for his doctrine except his own personal experience. Real authority is the authority which truth itself possesses, the truth which authenticates itself. Such truth has great power the power even of performing miracles (saccakiriyā), as shown in so many Jātaka stories, which are part of the Buddhist cultural heritage. Saddhā should, therefore be better translated as confidence, trust or conviction, rather than faith, because faith has involvements not found in the concept of Saddhā.

## សុភមង្គលនៃមនុស្សសត្វគ្រប់រូប
## HAPPINESS OF ALL BEINGS

មាគ៌ាជីវិតដែលព្រះសម្មាសម្ពុទ្ធសម្ដែង មិនមែនមានន័យពិសេសសម្រាប់តែបុគ្គលដែលរស់នៅក្នុងវត្តអារាមនោះទេ។ វាជារឿងត្រឹមត្រូវដែលថា បុគ្គលម្នាក់ៗត្រូវលះបង់នូវចិត្តជាប់ជំពាក់ដោយគ្រឿងសៅហ្មងទាំងឡាយ ដើម្បីសម្រេចនូវព្រះនិព្វាន ហើយព្រះសង្ឃអាចសម្រេចបានលឿនជាងគ្រហស្ថ។ ប៉ុន្តែ វាមិនត្រឹមត្រូវទាល់តែសោះ ដែលនិយាយ

ថា ព្រះសង្ឃអាចរួចចាកទុក្ខ ចូលកាន់ព្រះនិព្វាន រីឯគ្រហស្ថអ្នកគ្រប់គ្រងផ្ទះ មិនអាចរួចចាកទុក្ខបាននោះ។ ព្រះពុទ្ធវចនៈជាច្រើនដូចដែលប្រមូល និងចងក្រងដោយសង្គាយនា ដែលបានប្រារព្ធធ្វើឡើង ក្រោយពីព្រះអង្គទ្រង់ចូលបរិនិព្វាន មានមួយចំនួនធំពោលសំដៅលើព្រះភិក្ខុសង្ឃ ព្រោះលោកជាអ្នកទ្រង់បង្កើតឡើងដំបូង។ ប៉ុន្តែ ព្រះសូត្រជាច្រើនទៀត ទ្រង់សម្តែងចំពោះគ្រហស្ថផងដែរ។ ជូនកាល ចំពោះបុគ្គលតែម្នាក់ឯងក៏មាន។

The Way of Life taught by the Buddha is not, as sometimes suggested, meant specifically for those who live the monastic life. It is true that the spirituality of non-attachment which should be developed to attain Nibbāna could be achieved more quickly by the monk rather than by the layman. But, it is quite wrong to say that full liberation can be achieve only by the monk and not be the layman living a family life. The Buddha's discourses, as collected and edited by the Council of Elders which met after the Buddha's passing away, consist largely of sermons addressed to monks because it was they who mainly formed his immediate audiences. But, there are numerous discourses addressed to layman as well. Sometimes to a single individual.



នៅក្នុងពុទ្ធវចនៈដំបូងបង្អស់របស់ព្រះអង្គ ដែលហៅថា ការចាប់ផ្តើមនៃច្បាប់អំពើល្អ ព្រះអង្គទ្រង់សម្តែងពីទស្សនៈប្រកបដោយផលប្រយោជន៍ និងសេចក្តីសុខ របស់សត្វលោកទាំងអស់ ដោយសេចក្តីករុណាចំពោះសព្វសត្វ មិនមានការរើសអើង ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។ វាជាពេលដំបូងបំផុតក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស ដូចដែលយើងដឹងថា ជាទស្សនៈអំពើល្អទូទៅ ឬក៏ជាមនុស្សសមញ្ញ ប៉ុន្តែមនុស្សនៃពិភពលោក ហើយសូម្បីចំរុះជាតិសាសន៍នៃសាកលលោកក៏ដោយ។ វចនៈនេះត្រូវបានគេពិពណ៌នា ជាដំបូន្មានដែលផ្តល់ផលក្នុងពេលបច្ចុប្បន្ននេះ ដោយមិនពន្យារពេលវេលា មានន័យគ្រប់សម័យកាល ច្បាស់លាស់ និងការត្រួតពិនិត្យតាមដានទៀតផង។

In his very first sermon, called establishment of the Rule of Righteousness, he developed the conception of the welfare and happiness of all beings, without any discrimination whatsoever, 'out of compassion for the world'. It was the first time in human history, as we know, that the idea of a general good or a common man but also the peoples of the world and even more the inhabitants of the universe. It was also described as a teaching which gives results in this life, without delay, meant for all time, verifiable and inviting investigation.

# សាមគ្គីភាពនៃមនុស្សជាតិ

## UNITY OF MANKIND

ព្រះសម្មាសម្ពុទ្ធ មិនគ្រាន់តែបង្រៀនពីសារសំខាន់នៃការបដិវត្តផ្លូវក្នុងនៃបុគ្គលម្នាក់ៗ សម្រាប់សេចក្តីសុខនោះទេ ប៉ុន្តែសេចក្តីត្រូវការសម្រាប់បដិវត្តផ្លូវក្រៅ ក្នុងជីវិតនៃសង្គម ក៏ព្រះអង្គទ្រង់សម្តែងផងដែរ ។ ដូច្នេះ និយាយរួម ព្រះអង្គបានទ្រង់សម្តែងពីឯកភាពគ្នា និងសាមគ្គីភាពនៃមនុស្សជាតិ មិនប្រកាន់ពណ៌សម្បុរ, មិនប្រកាន់វណ្ណៈ ឬបុគ្គលិក-លក្ខណៈផ្សេងៗទៀត ដូចជា ក្នុងករណីនៃសត្វពាហនៈ និងបង្កើតការបដិវត្តសម្រាប់លុបបំបាត់ចោលនូវប្រព័ន្ធបុរាណ ដែលរីករាលដាលនៅប្រទេសឥណ្ឌា ក្នុងសម័យកាលរបស់ព្រះអង្គ ។ ក្នុងការបង្ហាញនូវទស្សនៈឯកភាពនៃមនុស្សជាតិ ព្រះអង្គបានបង្វែរទិស មិនត្រឹមតែព្រះមហាក្សត្រ អ្នកទីក្រុង ស្ត្រីអភិជនប៉ុណ្ណោះទេ ប៉ុន្តែអ្នកក្រីក្របំផុត ស្មូមយាចក កម្មករបោសសម្រាម អ្នកប្លន់ ផងដែរ ។

The Buddha taught not only the necessity of an inner revolution of the individual for human happiness but also the need for an outer revolution in the life of Society. Thus, for instance, he preached the fundamental oneness and unity of mankind, irrespective of colour or race or other physiological



characteristics- as in the case of animals- and created a revolution for the abolition of the cast system which was prevalent in India in his day. In order to demonstrate his concept of the oneness of mankind, he moved not only with kings and capitalists and aristocratic ladies, but also with the poorest of the poor, with beggars and scavengers, robbers and courtesans.

ព្រះអង្គបានបង្កើតសមាគមសង្ឃដែលមានទាំងបុរស និងស្ត្រី មកពីគ្រប់ឋានៈនៃសង្គម មិនគិតពីកំណើត ឬប្រភពដើម ។ ព្រះអង្គបានចាត់ចែងចំពោះអ្នកជម្ងឺ និងអ្នកទីទាល់ក្រ ជួយសម្រាលទុក្ខដល់បុគ្គលដែលមានរោគ និងនាំសេចក្តីសុខសុភមង្គលដល់អ្នកសោកសៅទាំងឡាយ ។ គេនិយាយថា មន្ទីរពេទ្យដំបូងក្នុងប្រវត្តិសាស្ត្រ បានបង្កើតឡើងតាមការណែនាំរបស់ព្រះអង្គ ។ ព្រះអង្គមិនបានចូលបរិនិព្វានពីពិភពលោកនេះក្រោយពីការត្រាស់ដឹងរបស់ព្រះអង្គទេ ប៉ុន្តែ ព្រះអង្គបានគង់ធរមាននៅអស់រយៈកាល ៤៥ ព្រះវស្សា ក្នុងសហគមន៍ ប្រមើលមើលបុគ្គលណាដែលអាចប្រោសបាន ។

He admitted into the Order (the Saṅgha) which he founded men and women from all grades of society, regardless of their birth or origin. He ministered to the sick and the destitute, consoled the stricken and

brought happiness to the miserable. It is said that the first hospitals in history were organized under his direction. He did not retire from the world after his Enlightenment but lived for forty-five years in the community, constantly seeking out those whom he could help.

## ប្រជាធិប្បតេយ្យ

## DEMOCRACY

ព្រះអង្គបានឱ្យតម្លៃខ្ពស់បំផុត ទៅលើសេរីភាពនៃបុគ្គល សេរីភាពនៃការបញ្ចេញមតិ ដំណោះស្រាយប្រជាធិបតេយ្យ។ ការប្រព្រឹត្តិចំពោះពុទ្ធសាសនា គឺមិនផ្ទុយទៅនឹងទស្សនៈបើកចំហនោះទេ។ សមាគមសង្ឃគឺត្រូវបានចាត់ទុកជាវិទ្យាស្ថានប្រជាធិប្បតេយ្យដ៏ចំណាស់បំផុត នៅក្នុងពិភពលោក ហើយត្រូវបានបង្កើតតាមទំរង់នេះ សម្រាប់សមាគមគ្រហស្ថរួមទាំងវិទ្យាស្ថាននយោបាយផងដែរ។ របៀបគ្រប់គ្រងរដ្ឋមានទិដ្ឋភាពប្រាកដឡើងក្នុងពុទ្ធសាសនា គឺប្រជាធិប្បតេយ្យ ការធ្វើការងារសម្រាប់សម្ភារៈ ការអប់រំសម្រាប់មនុស្ស ក្នុងការធានាបាននូវសុវត្ថិភាពនយោ-បាយ សេរីភាពជំនឿ និងបុគ្គល ក៏ដូចជាសុវត្ថិភាពសេដ្ឋកិច្ច ដោយមានការងារពេញលេញ។



He valued greatly the liberty of the individual, freedom the thought and expression and the ideals of democracy. A commitment to Buddhism is not contradictory to openness. The order of the Saṅgha is considered the oldest democratic institution in the world and it was set up as a model for lay organizations, including political institutions. The ideal state envisaged in Buddhism is a democracy, working for the material and spiritual welfare, for the people guaranteeing political, religious and personal freedom as well as economic security with full employment.

## ការខារសេដ្ឋកិច្ច

## ECONOMIC WELFARE

ផែនការសេដ្ឋកិច្ចត្រូវបានសង្កត់យ៉ាងជាក់ច្បាស់ថា ជាតួនាទីរបស់ព្រះមហាក្សត្រ ឬរដ្ឋ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា "នៅពេលណាសេដ្ឋកិច្ចរដ្ឋ ឬប្រទេសរីកចម្រើនរុងរឿង ល្អប្រពៃហើយ ប្រជាជនទាំងឡាយ ប្រាកដជាធ្វើដំណើរតាមបេសកកម្មផ្ទាល់របស់ខ្លួន នឹងមិនមានការរំខានរដ្ឋទេ រីឯពន្ធដារចូលរដ្ឋក៏នឹងកើនឡើង ប្រទេសនឹងមានភាពស្ងប់ស្ងាត់ សុខសន្តិភាព ហើយប្រជារាស្ត្រថ្នាក់ទាប ក៏សប្បាយរីករាយដាក់គ្នាក្រសោបឱបកូនរបស់ពួកគេនៅក្នុងរង្វង់ដៃ នឹងរស់នៅប្រកបដោយសេរី-

ភាព"។ ក្នុងពុទ្ធដីកាមួយកន្លែង លោកមហាវាស្តុនិយាយថា "ពិភពលោកនេះពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះពីរយ៉ាង គឺទ្រព្យសម្បត្តិ និងការថែរក្សានូវអ្វីដែលខ្លួនរកបានមក។ ដូច្នេះ ចំពោះតម្រូវការទ្រព្យសម្បត្តិ និងថែ-រក្សាការពារនូវអ្វីដែលអ្នករកបានមក ត្រូវមានព្យាយាមអស់ពីសមត្ថភាពមួយអន្លើដោយអំពើល្អ"។

Planning for economic welfare is clearly emphasized as part of the functions of the king or the state. "When that is properly done, says the Buddha, the inhabitants, following each his own mission, will no longer harass the realm, the state revenue will increase, the country will be quiet and at peace and the populace, please with one another and happy, dancing their children in their arms will dwell with open doors." A Buddhist text, the Mahāvastu, says, "The world rests on two foundations: the acquisition of wealth not acquired and the conservation of what is gained. Therefore to acquire wealth and conserve what you have gained, make firm efforts, within the bounds of righteousness."

## កម្មសិទ្ធិលើទ្រព្យសម្បត្តិ
## OWNERSHIP OF PROPERTY



កម្មសិទ្ធិទ្រព្យសម្បត្តិសាធារណៈ ត្រូវបានគេពេញចិត្តក្នុងផ្នែកជាច្រើននៃពិភពលោក។ ជាពិសេសនៅទីកន្លែងណាដែលគោលការណ៍សង្គមមានស្ថិរភាព។ ដូចយើងបានដឹងស្រាប់ហើយ អាកប្បកិរិយា ការប្រព្រឹត្តិ និងការតាក់តែងគោលការណ៍ច្បាប់កម្មសិទ្ធិធម្មតាក្នុងសង្គម ឬសហគមន៍ជាក់លាក់ដំបូង ត្រូវបានគេឃើញក្នុងព្រះវិន័យដែលគ្រប់គ្រងព្រះភិក្ខុ-សង្ឃ ជាកន្លែងដែលទ្រព្យសម្បត្តិទាំងអស់ ទោះជាចលនៈទ្រព្យក្តី អចល-នៈទ្រព្យក្តី ជាតម្លៃសេដ្ឋកិច្ចដ៏សំខាន់ ត្រូវបានរៀបចំទុកដាក់ដោយសេចក្តីស្មោះត្រង់ គ្មានលក្ខណៈចាំបាច់ណាមួយនោះទេ។ ជីវិតនៅក្នុងសង្គមសង្ឃគឺជាជីវិតដែលប្រកបដោយភាពព្រមព្រៀងគ្នា ផ្អែកតាមព្រះវិន័យជាគោលសហប្រតិបត្តិការស្ម័គ្រចិត្ត។

Public ownership of property is favoured in many parts of the world. Especially where socialist principles hold sway. As far as it is known, the first consistent and thorough-going application of the principle of common ownership in a specific community or society is to be found in the Vinaya rules which govern the Order of the Buddhist Saṅgha, where all property moveable and immovable, of any significant economic value, is held in common trust, without any sort of compulsion. Life in the Saṅgha is a corporate life based on the principles of voluntary co-operation.

# ព្រះពុទ្ធសាសនា និង មនុស្សជាតិ
## BUDDHISM AND MANKIND

បន្តពីអ្វីដែលបាននិយាយរួចមកខាងដើម យើងប្រាកដជានឹងយល់ថា ពុទ្ធសាសនាគឺមានទំនាក់ទំនងយ៉ាងជិតបំផុត ទៅនឹងពិភពលោក និងជីវិតនៃមនុស្សជាតិនេះ។ ព្រះពុទ្ធសាសនាមិនមែនជាសាសនាដែលប្រឆាំងនឹងពិភពលោកនោះទេ។ ព្រះសម្មាសម្ពុទ្ធបានសម្តែងពីពាក្យប្រៀនប្រដៅរបស់ព្រះអង្គថា ដូចជាសន្ទិដ្ឋិកធម៌ ដែលជាធម៌មានទាក់ទងយ៉ាងចម្បង ជាមួយនឹងពិភពលោក និងបច្ចុប្បន្នជាតិនេះឯង។ សូម្បីតែអតិបរមសុខ ពោលគឺ ព្រះនិព្វានក៏ត្រូវបានតស៊ូព្យាយាមក្នុងជាតិនេះ។ ព្រះនិព្វាននេះសង្កត់ធ្ងន់បំផុតទៅលើតម្រូវការដាច់ខាតមួយ ពោលគឺត្រូវធ្វើនូវសេចក្តីព្យាយាមប្រឹងប្រែង នៅក្នុងពេលបច្ចុប្បន្នដ៏លឿនរហ័សនេះ ដើម្បីឱ្យពេលអនាគតកាល ត្រូវគ្រប់គ្រងភាពជាមនុស្សរបស់យើង។ អតីតកាលជាពេលដែលកន្លងផុតទៅហើយ មិនអាចហៅឱ្យវិលមកវិញបានទេ។ មានតែពេលបច្ចុប្បន្នប៉ុណ្ណោះ ដែលសមប្រកបចំពោះយើងសម្រាប់ដឹកនាំជីវិតឱ្យបានប្រពៃថ្លៃថ្លា។ អនាគតកាល ក៏ជាពេលដែលមិនទាន់មកដល់ដែរ ហើយអ្វីដែលយើងធ្វើ វានឹងជាប់តាមយើងជានិច្ច។

From what has been said already, it will be seen the Buddhism is very much concerned with this world



and the life of mankind therein. It is by no means a world-denying religion. The Buddha described his teaching as being Sandiṭṭhika, primarily concerned with this world, with this life. Even the highest happiness, that of Nibbāna, is to be striven for in this very life. It lays the greatest stress on the absolute need for making the best of the ever-fleeting present, so as to ensure that the future is controlled for our well-being. The past is gone beyond recall. Only the present is available to us for the good life. The future is yet to come and what we make of it depends entirely on us.

ពុទ្ធសាសនិកមិនត្រូវចាត់ទុកពិភពលោកជាគុក ដែលមនុស្សត្រូវតែគេចវេស ដើម្បីចូលទៅកាន់ឋានសួគ៌នោះឡើយ។ ជាងនេះទៅទៀត គាត់ស្វែងរកការកសាងឋានសួគ៌នៅទីនេះ។ មនុស្សមិនមែនជាអ្នកសម្ភារៈនិយម ទាំងមិនមែនជាអ្នកបដិសេធចោលនូវគុណតម្លៃនៃទ្រព្យសម្បត្តិនោះដែរ។ បញ្ហារបស់មនុស្សមិនមែនស្ថិតនៅត្រង់ជម្រើសរវាងអារម្មណ៍និងចិត្តទេ ប៉ុន្តែជាជម្រើស រវាងការត្រួតត្រានៃដួងចិត្ត។ ដំណោះស្រាយរបស់ពុទ្ធសាសនិក គឺត្រូវបង្កើតតុល្យភាពរវាងបរិយាកាសខាងក្រៅ និងបរិយាកាសខាងក្នុង, រវាងធម្មជាតិខាងក្រៅ និងខាងក្នុង និងពិភពលោកដែលនៅជុំវិញខ្លួនយើង ដំណើរការដួងចិត្ត ឆ្លងកាត់ការច្បាំងដណ្តើមគ្នានៃភាពអាត្មានិយម។ ជីវិតគឺជាដំណើរផ្សងព្រេងដ៏អស្ចារ្យបំផុត ចំពោះ

មនុស្សគ្រប់រូប ហើយជារឿយៗ ជាដំណើរដ៏ពោរពេញដោយគ្រោះថ្នាក់ណាស់ ។ បញ្ហាចម្បងគឺថា តើដំណើរផ្សងព្រេងដ៏អស្ចារ្យបំផុតទាំងអស់នេះអាចត្រូវតម្រង់ទិសទៅរកសេចក្ដីសុខសប្បាយ នៅទីបញ្ចប់ដោយរបៀបណា ។

The Buddhist does not regard the world as a prison from which man must escape to enter heaven. Rather, he seeks to build heaven here. He is not a materialist, nor does he scorn the advantages of a material civilization. His problem is not that of a choice between the senses and the spirit but a choice between the domination of the spirit. The Buddhist ideal is to establish an equilibrium between the outside and the inside, between the externalities and of nature and the world around us and the spiritual progress through the conquest of the selfishness. To him, life is a great adventure, often a dangerous adventure. The main problem is how this greatest of all adventures could be directed to a happy ending.

## សេចក្ដីបរិសុទ្ធ
## PERFECTION



ឧត្ដមគតិពុទ្ធសាសនិក គឺព្រះអរហន្ត ពោលគឺសេចក្ដីបរិសុទ្ធ ជាកន្លែងដែលមានមនុស្សបរិសុទ្ធទាំងផ្លូវកាយ និងផ្លូវចិត្ត ។ ដើម្បីសម្រេចនូវគោលដៅនេះ កត្តាទាំងអស់ដែលប្រឆាំងនឹងមនុស្សបរិសុទ្ធប្រភេទនេះច្បាស់ជាត្រូវកម្ចាត់បង់ហើយ មិនមែនសម្រាប់តែខ្លួនឯងទេ ប៉ុន្តែសម្រាប់ភាវៈទាំងអស់ដែលមានជីវិត ។ ពុទ្ធសាសនិកមិនអាចស្វែងរកប្រយោជន៍សម្រាប់តែខ្លួនឯង ហើយព្រងើយកន្តើយផលប្រយោជន៍អ្នកដទៃនោះទេ ។ កិច្ចការរបស់គាត់ ត្រូវផ្សារភ្ជាប់ជាមួយកិច្ចការនៃពិភពលោកទាំងមូល ។ ចំណុចនេះ ពុទ្ធដីកាទ្រង់សង្កត់ធ្ងន់ថា មនុស្សល្អត្រូវតែជា *សព្វបនភូត-ហិតនុកម្បិ* ដែលជាអ្នកជាប់ទាក់ទងយ៉ាងជ្រៅទៅនឹងការងារដ៏សកម្មសម្រាប់សេចក្ដីសុខ ហើយកិច្ចការនេះទៀតសោត មិនមែនសម្រាប់តែមនុស្សជាតិនោះឡើយ ប៉ុន្តែសម្រាប់ភាវៈរស់ទាំងអស់ផងដែរ ។

The Buddhist ideal is that of arahantship, i.e. perfection, where there is perfect well-being of both body and mind. To achieve this ideal, all those factors that militate against such well- being must be moved, not only for oneself but also for all things that have life. The Buddhist cannot seek his personal welfare, regardless of others; his welfare is inextricably bound up with the welfare of the whole world. Hence the Buddha's injunction that the good man must be sabba-panabhuta- hitanukampi, deeply concerned with and

actively working for the happiness and welfare not only of human beings but of all living creatures.

## គុណធម៌ ២ ប្រការ

### TWIN VIRTUES

នៅពេលណាព្រះពុទ្ធសាសនារកឃើញនូវមាគ៌ារបស់ខ្លួន, ពុទ្ធសាសនាបានលើកកំពស់កំណើនអារ្យធម៌ និងវប្បធម៌ ដែលត្រូវបានគេកំណត់ដោយខន្តី សេចក្តីអត់ធន់ មនុស្សជាតិ មុទិតា និងសេចក្តីយល់ឃើញត្រូវ គុណធម៌ពីរប្រការ ករុណា សេចក្តីអាណិតអាសូរ និងបញ្ញា ដែលបង្កើតពុទ្ធវចនៈដ៏ចម្បងទាំងពីរប្រការនេះ ។

Whenever Buddhism found its way, it encouraged the growth of a civilization and a culture marked by tolerance, humanity, sympathy and understanding, the twin virtues of karunā (compassion) and paññā (wisdom) which form the two main plank of the Buddhist doctrine.

## ពិភពលោកទំនើបកម្ម

### THE MODERN WORLD



សមិទ្ធកម្មផ្សេងៗគ្នានៃពិភពលោកទំនើបកម្មនេះ គឺជាការបង្កើនល្បឿន និងទំហំនៃដំណើរការផ្លាស់ប្តូរ ។ សព្វថ្ងៃនេះ យើងទទួលស្គាល់ថាការផ្លាស់ប្តូរដ៏កំហ៊ុកដែលស្ទើរតែមិនអាចជឿបាន និងខុសប្លែកពីធម្មតានៃសង្គមមនុស្សជាតិទាំងអស់ គ្រប់សកម្មភាពរបស់មនុស្ស ។ វាជាការពិតដែលថា ចលនាដំណើរទៅមុខនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានបំបែកនូវចំណតដ៏រឹងមាំនៃមាគ៌ាជីវិត ដែលមានលក្ខណៈអភិសមាចារផ្ទាល់របស់ខ្លួន ហើយចំនួននៃមនុស្សយ៉ាងច្រើនបណ្តោយតាមយថាកម្ម នៅក្នុងពិភពលោកដ៏ចម្លែក និងលំបាក ។ ពិភពលោកនេះ គឺប្រែប្រួលយ៉ាងរហ័ស ហួសពីការកត់សម្គាល់ ។

The distinctive feature of the modern world is the acceleration and magnitude of the process of change. We witness today almost unbelievable change in the drastic and revolutionary transformation of all human institutions in every field of human activity. It is true that the breath-taking advances of science and technology have destroyed the solid moorings of a more stable way of life, which had its own ethical character, and cast large masses of men adrift in a strange and difficult world. The world is fast changing out of recognition.

ប៉ុន្តែចលនាទៅមុខទាំងនេះ បាននាំមកនូវការជួយសម្រាលទុក្ខលំបាកដល់មនុស្សជាតិជាច្រើនផ្នែកផងដែរ។ ពួកគេបានផ្តល់ប្រយោជន៍ដល់យើងយ៉ាងច្រើនទាំងផ្នែកសម្ភារៈ និងស្មារតី និងជួយកម្ចាត់បង់នូវសេចក្តីស្រេកឃ្លាន និងភាពក្រីក្រ។ វិទ្យាសាស្ត្រត្រូវបានច្របាច់ចូលគ្នាកាន់តែកៀក ជាងពេលអតីតកាល ហើយបានផ្តល់នូវទំនួលខុសត្រូវចំពោះតម្រូវការ និងការទាមទាររបស់មនុស្ស។ ទោសកំហុសមិនមែនស្ថិតនៅក្នុងផលិតផលនៃដំណើរការទៅមុខរបស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានោះទេ ប៉ុន្តែ វាស្ថិតនៅក្នុងភាពបរាជ័យរបស់យើង ដែលប្រើប្រាស់វា មិនប្រកបដោយបញ្ញា និងមិនបានត្រឹមត្រូវប៉ុណ្ណោះ។

But these advances have also brought emancipation to humanity in many directions. They have given us great social and intellectual gains and the means whereby to destroy hunger and poverty. Societies have been knit together closer than ever before, and made more responsive to men's needs and demands. The fault will not be in the products of scientific and technical advance but in our failure to make wise and proper use of them.

## ពិភពលោកប្រែប្រួល
## THE CHANGING WORLD



ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា ក្នុងករណីណាក៏ដោយ យើងមិនអាចបញ្ឈប់ពិភពលោកបានទេ វានឹងបន្តដំណើរប្រែប្រួលនេះ ចំពោះការប្រែប្រួលផ្លាស់ប្តូរនេះ គឺជាកត្តាគ្រឹះនៃជីវិត។ មិនមានបដិវត្តន៍ណាអាចបញ្ចប់ការប្រែប្រួលខ្លួនវានោះឡើយ។ នោះគឺជាសម្ផស្សនៃការប្រែ-ប្រួល។ ដោយសារការផ្លាស់ប្តូរមិនមានឈប់ឈរនេះហើយ ទើបការបដិវត្តកាលពីម្សិលមិញ ក្លាយជាទំនៀមទម្លាប់នាពេលបច្ចុប្បន្ននេះ ហើយទំនៀមទម្លាប់បច្ចុប្បន្ន គឺជាអំពើកំណាចនាថ្ងៃស្អែក។ គ្រប់ដំណើរការរស់នៅរបស់យើងត្រូវចងភ្ជាប់ជាមួយនឹងការផ្លាស់ប្តូរ។ នេះជាទីកន្លែងដែលមនុស្សសម័យទំនើបកម្ម ត្រូវតែស្វែងរកពុទ្ធសាសនា មកធ្វើជាទីពំនាក់អាស្រ័យយ៉ាងជាក់លាក់ក្នុងជីវិតរបស់គាត់។ ពុទ្ធសាសនាទទួលស្គាល់ការប្រែប្រួល តាមពិតការប្រែប្រួល និងផ្លាស់ប្តូរនេះ ជាសច្ចភាពមួយ។ យើងត្រូវតែសិក្សាពីទឹកស្ទឹងដែលហូរជានិច្ច។

In any case, we cannot stop the world; it will go on changing, for change, says the Buddha, is the fundamental fact of life. No revolution can put an end to change itself. That is the beauty of change. Without constant change, yesterday's revolution becomes today' convention and today's convention is tomorrow's tyranny. Our very survival is tied up with the change. This is where modern man must find

Buddhism to be particularly relevant to his age. Buddhism accepts change; in fact, it is built on the truth of constant change and flux. We must learn to take the rivers as they flow.

យើងត្រូវតែសិក្សារៀនសូត្រ នូវគុណតម្លៃនៃការក្រោកឈរឡើង, សមត្ថភាព ដើម្បីយល់ព្រម, សម្របតាម និងអាចបត់បែនតាមបាន។ នៅពេល យើងប្រកាន់យកការសន្និដ្ឋានមិនអាចប្រែប្រួល នឹងបដិសេធ មិនធ្វើការពិចារណាថ្លឹងថ្លែងនូវទស្សនៈផ្សេងៗ នោះយើងច្បាស់ជាបាត់បង់នូវភាពវៃឆ្លាត។ គំនិតរបស់យើងលំអៀងទៅខាងសេចក្ដីទុក្ខងាប់ក្រឡា ហើយការងាប់ក្រឡានេះឯង ធ្វើឱ្យយើងរឹងក្បាលក្នុងភាពចចេសរឹងរូសរបស់យើង។ ការប្រកួតប្រជែងថ្មី អំពាវនាវរកនូវទំនួលខុសត្រូវក៏ថ្មីដែរ។ ប្រសិនបើ បុគ្គលម្នាក់ៗយកចិត្តទុកដាក់ចៀសវាងពីជំនឿងាប់ក្រឡា នោះសហគមន៍ក៏ក្លាយជាសង្គមទូលំទូលាយ ដែលញ៉ាំងជីវិតដ៏ល្អ ឱ្យប្រព្រឹត្តទៅងាយ។

We must cultivate the quality of resilience, the ability to adopt, adapt and be flexible. The moment we come to rigid conclusions and refuse to consider different points of view, we cease to be intelligent. Our views tend to harden into dogmas and dogmas make us mulish in our obstinacy. New challenges call for new responses. If each individual takes care to avoid



dogmas, the entire community becomes an open society which makes the good life possible.

## បញ្ហាដែលមនុស្សជាតត្រូវប្រឈម
PROBLEMS FACING MANKIND

បញ្ហាដែលនៅមុខមនុស្សជាតិ គឺមានចំនួនច្រើនណាស់។ យើងមានបញ្ហានៃទ្រព្យ, ឧស្សាហកម្ម, ការងារ, ប្រាក់ខែ, ភាពគ្មានការងារធ្វើ, ភាពគ្មានសំណាង, គំលាតរវាងមាន និងក្រ ប៉ុន្តែពិពណ៌នាបានត្រឹមតែពីរបីប៉ុណ្ណោះ។ បញ្ហាទាំងនោះបានកើតឡើងស្មុគស្មាញណាស់ ទៅតាមតថ-ភាពពិតរបស់វា ប៉ុន្តែមហិច្ឆតានៃមនុស្សសាមញ្ញ គឺជារឿងធម្មតាមួយ។ គាត់ប្រាថ្នាចង់រស់នៅតែក្នុងសុខសន្តិភាព សេរីភាព ប៉ុណ្ណោះ ដើម្បីកសាងនូវពិភពដ៏តូចមួយផ្ទាល់ខ្លួន នៅក្នុងភាពជាមនុស្សជាតិ។

The problems facing mankind are many. We have problems of goods, industry, labour, wages, unemployment, inequality of opportunity, the gap between the haves and the have-nots, to mention but a few. They appeared very complicate, as indeed they are, but the aspiration of the common man is a simple one. He merely wishes to be able to live in peace and happiness, with freedom to build his own little world, in human dignity.

គាត់ត្រូវការមិត្តភាព, ចំណេះដឹង, សេចក្ដីស្រឡាញ់, និងវត្ថុផ្សេងទៀត ដែលនឹងផ្ដល់នូវក្ដីសង្ឃឹមដល់ខ្លួនគាត់ និងកូនចៅរបស់គាត់ ទាំងក្នុងជាតិនេះ ទាំងជាតិខាងមុខ។ នៅផ្នែកខ្លះនៃពិភពលោក តម្រូវការមូលដ្ឋានទាំងនេះ មិនអាចដំណើរការបានឡើយ។ គេមើលឃើញផ្នែកទាំងនោះគ្មានសុវត្ថិភាព គ្មានយុត្តិធម៌ ជាសាកលទៅហើយ។ សេចក្ដីមិនពិត និង អសន្តិសុខ បានក្លាយជាបណ្ដាសារសាកលលោក ស្ទើរក្ស័យជីវិត ទាំងក្នុងចំណោមអ្នកមាន ទាំងអ្នកក្រ ដែលជួនកាលបង្កើតឱ្យមានភាពមិនរវីរវល់ និងភាពព្រងើយកន្ដើយ, ជួនកាលមានកោលាហល, ភាព-តានតឹង និងការបដិវត្ត។ វិទ្យាសាស្ត្រស្រាវជ្រាវរាវរកមិនឃើញនូវអាថិកំបាំងនៃសេចក្ដីសុខសុមង្គលទេ។ "ការច្បាំងដណ្ដើមនឹងធម្មជាតិ" មិនបាននាំមកនូវភាពសម្បូរសប្បាយ ឬសុខសន្តិភាពនោះទេ។ នេះមិន-មែនជារឿងគួរឱ្យភ្ញាក់ផ្អើលសម្រាប់យើងឡើយ ព្រោះព្រះសម្មាសម្ពុទ្ធបានបង្រៀនយើងថា សេចក្ដីសុខកើតមាន លុះត្រាតែយើងរស់នៅប្រកបដោយធម៌សាមគ្គី ពោលគឺរស់នៅជាមួយធម្មជាតិ, ជាមួយសម្រស់ និងភាពរុងរឿងរបស់វា។ សេចក្ដីពិត គឺនៅត្រង់ថា មនុស្សជាតិទាំងមូលនេះជាទុក្ខ ជាសេចក្ដីសោកសៅដែលមិនអាចបំបែកចេញបានទៀតផង។

He also needs fellowship, understanding, love, and something that will provide hope for himself and



his children, both for this life and in the next. In many parts of the world, even these basic needs are not available. Neither security nor justice is to be found universally. Uncertainty and insecurity have become a deadly almost universal curse, both among the rich and the poor, producing sometimes apathy and indifference, sometimes unrest, tension and revolution. Science has failed to find the secret of happiness. The "conquest of nature" has not succeeded in achieving either plenty or peace. This is not surprising to us, because the Buddha taught us that happiness is to be found in living in harmony with the Dhamma, i.e. with Nature, with its beauty and grandeur. The truth is that humankind, as a whole, is unhappy, desperately miserable.

ដូច្នេះ ស្ថានភាពនេះទំនងជាស្មុគស្មាញបំផុត ហើយប្រហែលជាមិនមានដំណោះស្រាយទៀតផង។ ប៉ុន្តែ ប្រសិនបើយើងសង្កេតពិនិត្យបញ្ហានេះ ដោយប្រុងប្រយ័ត្នជាមួយនឹងបញ្ញា និងការយល់ត្រូវ យើងនឹងដឹងច្បាស់ថា បញ្ហាសម័យថ្មីរបស់យើង គឺគ្មានមូលដ្ឋានណាផ្សេងពីបញ្ហាដែលកើតឡើងដ៏យូរនោះទេ ដែលវាបានធ្វើឱ្យមនុស្សរងទុក្ខវេទនា នៅគ្រប់ពេលវេលា និងគ្រប់បរិយាកាស។ ប្រសិនបើ បញ្ហានាសម័យទំនើបរបស់យើងនេះ ខុសដោយឡែកពីបញ្ហានៃជីដូនជីតារបស់យើង នោះវាគឺ

កាន់តែរីកធំឡើងៗជាងបញ្ហារបស់ដូនតា និងផ្សេងៗគ្នា ក៏រឹងរឹតតែច្រើនទៀត។

The situation, therefore, would appear to be extremely complicate and probably incapable of solution. Yet, if we were to examine the matter carefully, with knowledge and understanding, we should realize that our modern problems are not fundamentally different from the perennial problems that have afflicted people at all times and in all climes. If our modern problems differ from those of our forebears, it is largely in the matter of their greater number and wider variety.

ឥឡូវនេះ យើងបានយល់រួចមកហើយ ពុទ្ធដីកាគ្រឹះមួយ គឺថា មិនមានអ្វីកើតឡើង ក្រៅតែពីផលនៃហេតុបច្ច័យនោះទេ។ នៅពេលណាមួយ គេបានស៊ើបអង្កេតនូវហេតុបច្ច័យច្បាស់លាស់ និងបានយល់ច្បាស់ពេលនោះ គេក៏អាចរកឃើញនូវដំណោះស្រាយផងដែរ។ ជារឿយៗ គេតែងតែនិយាយថា ពាក្យទូន្មានប្រៀនប្រដៅនៃបណ្ឌិតបុរាណទាំងឡាយដូចជាព្រះសម្មាសម្ពុទ្ធជាដើម គឺសាមញ្ញ និងមានប្រសិទ្ធភាពគ្រប់គ្រាន់ដើម្បីជួយយើងទាំងអស់គ្នា នៅក្នុងដំណោះស្រាយនៃបញ្ហាដ៏ស្មុគស្មាញដែលបានជះឥទ្ធិពលមកបុគ្គលម្នាក់ៗ និងសង្គមជាតិទាំងមូល ក្នុងជីវិត



ស្របាលគ្នានេះ។ គេបានប្រកាសពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធថា ជាក្រមតក្កវិទ្យាមនុស្សជាតិ ហើយទ្រឹស្តីនេះត្រូវគ្រប់សម័យកាល និងគួរដល់នូវពេលវេលា។ វាជាមគ្គុទ្ទេសក៏ ចំពោះសកម្មភាពទាំងឡាយមាន មនោ-កម្ម វចីកម្ម និងកាយកម្ម។ ជំនាន់ដែលជោគជ័យនីមួយៗត្រូវតែស្រាវ-ជ្រាវរកឡើងវិញ នូវភាពទាក់ទងគ្នានៃពាក្យទូន្មាននោះ ដើម្បីជាដំណោះស្រាយនៃបញ្ហាផ្ទាល់ខ្លួន។

Now, the fundamental teaching of the Buddha, as we have seen already, is that nothing happens except as a result of causes. Once the causes are investigated and understood, the solutions could be found. It is all too frequently assumed that the teachings of ancient sages, such as the Buddha, are too simple to be efficacious enough to help us in the solution of the exceedingly complex problems which affect the individual and society in contemporary life. The message of the Buddha is addressed to the basic human predicament and this makes it both timeless and timely. It is a guide to action in terms of thought, word and deed. Each succeeding generation can and must rediscover the relevance of that message to the solution of its own problems.

# អតបរមសុខ

## HIGHEST HAPPINESS

មានតែពុទ្ធវចនៈទេដែលថា *អតិបរមសុខ* គឺជាសេចក្តីស្ងប់ ហើយ មិនអាចមានសេចក្តីសុខពិតប្រាកដឡើយ បើគ្មានសេចក្តីស្ងប់។ ពិភព-លោករវើរវាយជាមួយនឹងសេចក្តីភ័យខ្លាច និងការគំរាមកំហែងនៃសង្គ្រាម។ ប្រទេសទាំងឡាយដែលមានជាប់ទាក់ទងនឹងការធ្វើសង្គ្រាម បានក្លាយជាឃ្លាំងអាវុធនៃយោធាដែលគួរខ្លាចញញើត, ដោយបានធានាបន្តនូវពាណិជ្ជកម្ម និងផលចំណេញ ចំពោះពាណិជ្ជករនៃមរណភាព និងការបំផ្លិចបំផ្លាញ មនោគមវិជ្ជាឈ្លោះប្រកែកទាស់ទែងខ្វែងគំនិតគ្នាជាបន្តបន្ទាប់។ មិនត្រឹមតែក្រុមកងយោធាប៉ុណ្ណោះទេ ប៉ុន្តែប្រជាជនប្រុសស្រី និងកូនក្មេង ដែលមិនមានកំហុសរាប់ពាន់នាក់ត្រូវបានសម្លាប់រង្គាល យ៉ាងសាហាវព្រៃផ្សៃបំផុត។ ការខូចខាតដែលមិនអាចគណនាបាន ប៉ះពាល់មកលើដី និងទ្រព្យសម្បត្តិ។ គ្មានអ្វីគេចផុតពីអំពើឃោរឃៅ និងការឈ្លក់-វង្វេងនៃសមរភូមិឡើយ ហើយតើអ្វីត្រូវបញ្ចប់? ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា "ពៀរមិនដែលរម្ងាប់ ដោយការចងពៀរទេ តែត្រូវរម្ងាប់ដោយសេចក្តីស្រឡាញ់ (មេត្តា)" ហើយមួយវិញទៀត "អ្នកឈ្នះតែងប្រ-ទះនូវពៀរ រីឯអ្នកចាញ់ដេកជាទុក្ខ"។ នៅក្នុងផ្នែកផ្សេងទៀតនៃពិភព-



លោក ភ្លើងសង្គ្រាមបានរំកិលមកជិតដោយគំរាមកំហែង។ បរិយាកាសពោរពេញដោយអំពើហិង្សា ទាំងផ្លូវចិត្ត ផ្លូវវាចា និងផ្លូវកាយ។

It is the Buddha's teachings that the highest happiness is peace and that there can be no real happiness without peace. The world is distraught with fears and threats of wars. Countries involved in war have become awesome arsenals of military hardware, ensuring continued business and profit to merchants of death and destruction: following conflicting ideologies. Not only military personnel but thousands of innocent men, women and children are being mercilessly massacred and incalculable damage inflicted on land and property. Nothing escapes the fury and the frenzy of battle, and to what end? "Hatred never ceases by hatred," declared the Buddha, " but only by love", and again, " victory breeds ill-will, for the conquered are unhappy. In many other parts of the world, war-clouds hang menacingly near. The air is full of violence in thought, word and deed.

# មូលហេតុនៃសង្គ្រាម

## ROOT-CAUSES OF WAR

ព្រះសម្មាសម្ពុទ្ធបង្រៀនយើងទាំងអស់គ្នាផងដែរថា មាគ៌ាតែមួយគត់ដែលនាំឱ្យសម្រេចបាននូវសេចក្តីស្ងប់ គឺតាមរយៈការលះបង់នូវឫសគល់នៃសង្គ្រាមមាន លោភៈ ទោសៈ និងមោហៈ។ បច្ចុប្បន្ននេះពិភពលោកត្រូវចែកចេញជាផ្នែកមនោគមវិជ្ជាផ្សេងៗ ជាមួយនឹងអំណាចរបស់ពួកគេ ក្រុមបក្សសម្ព័ន្ធ ដែលបូជាកំលាំងកាយ ទាំងកំលាំងចិត្តចំពោះនិទ្ទោស ភាពអវិជ្ជមាន ជំនួញខុសច្បាប់នៃសង្គ្រាម។ ពិភពលោកមិនមានសន្តិភាពទេ ដរាបណាមនុស្ស និងប្រជាជាតិទាំងឡាយមិនលះបង់ចោលនូវបំណងប្រាថ្នាអាត្មានិយម ភាពក្រអើតក្រទមជាតិសាសន៍ និងមិនជម្រះចោលនូវភាពអាត្មានិយមចំពោះទ្រព្យសម្បត្តិ និងអំណាច។ មនោគមវិជ្ជាត្រូវចែកចេញដូចតទៅ: មនោគមវិជ្ជានាំមកនូវជម្លោះ, មនោគមវិជ្ជាមានទំរង់ច្រើនប្រការ ដូចជា នយោបាយ, សាសនា, សេដ្ឋកិច្ច, សង្គមកិច្ច និងការអប់រំ។ មនោគមវិជ្ជា គឺជាវិជ្ជា គេចចេញពីសច្ចភាព។ វាធ្វើឱ្យមនុស្សសាហាវឃោរឃៅ និង ចងរិតមនុស្សឱ្យជាប់នៅក្នុងភាពនិយមជ្រុល និងអំពើហិង្សា។

The Buddha also teaches us that the only way to achieve peace is by eliminating the root-causes of war-greed, hatred and ignorance. Today the world is divided into various ideologies, with their power, blocs, who devote most of their minds and energies to



the sterile, negative, stupid business of wars. The world cannot have peace till men and nations renounce selfish desires, give up racial arrogances and clean themselves of the egoistical lust for possession and power. Ideology divides; it brings about conflict. Ideology takes multifarious form – political, religious, economical, social and educational. Ideology is an escape from reality. It brutalizes man and holds him in bondage to fanaticism and  violence.

មនោគមវិជ្ជាជម្លោះចាប់បដិសន្ធិក្នុងចិត្តរបស់មនុស្ស ដែលចេញផ្លែផ្កាជាភាពតានតឹង និងសង្គ្រាម ហើយមនោគមវិជ្ជាទាំងនេះ ត្រូវតែកម្ចាត់ចេញពីចិត្តរបស់មនុស្ស ដើម្បីឱ្យមនុស្សជាតិអាចពេញបរិបូរដោយគំនិតសាមគ្គីភាព និងសន្តិភាព។ ព្រះសម្មាសម្ពុទ្ធបានទ្រង់ត្រាស់សម្តែងថា "ធមិទាំងឡាយមានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្តទោះល្អក្តី ទោះអាក្រក់ក្តី ព្រោះហេតុនោះ បើបុគ្គលបានជម្រះនូវចិត្តចេញពីគ្រឿងសៅហ្មង សេចក្តីស្ងប់ និងសេចក្តីសុខសុភមង្គល នឹងកើតមានពិតប្រាកដ"។

It is in men's minds that conflicting ideologies are born, resulting in tension and war and it is from the minds of men that these conflicts should be eradicated so that humanity could be filled with thoughts of harmony and peace. The Buddha declared that the mind is foremost, the forerunner of all things, good or

bad, that, when the mind is cleansed of evil, peace and happiness will reign.

## ចិត្តប្រែប្រួល

## CHANGE OF HEART

បន្ទាប់មក នេះជាកាតព្វកិច្ចរបស់សាសនា ពោលគឺ សាសនាទាំងអស់។ មានតែសាសនាមួយប៉ុណ្ណោះ ដែលអាចមានឥទ្ធិពលទៅលើចិត្តវិប្បលាសនេះ គឺសាសនាដែលមិនស្ថិតក្នុងការអនុវត្តវិធីបូជាបួងសួង និងការសូត្រអធិដ្ឋាន ប៉ុន្តែស្ថិតក្នុងជីវិតបរិសុទ្ធ និងសេចក្តីស្ងប់ចិត្ត ដែលជាហេតុបណ្តាលឱ្យមានការទម្លាក់សព្វាវុធនៃចិត្ត ពោលគឺជាការដកសព្វាវុធពិតប្រាកដមួយ។

This, then, is the task of religion- all religions. It is religion alone that can affect the necessary change of heart – religion which consists not in the performance of rites and ceremonies and the preaching of sermons, but in a life of holiness and inner tranquility, resulting in the disarmament of the mind, which is the only real disarmament.

## សាសនាពិត

## TRUE RELIGION



សាសនាត្រូវតែយកសង្គមមនុស្សទាំងមូល ទុកដូចជាខេត្តរបស់ខ្លួន ប្រសិនបើ វាជាសាសនាពិតប្រាកដនោះ ហើយមិនមែនគិតត្រឹមតែជីវិតរបស់ខ្លួនប៉ុណ្ណោះឡើយ។ មនុស្សល្អ ជាមនុស្សដែលអនុវត្តតាមសាសនារបស់ខ្លួន, ជាមនុស្សដែលដឹងថា មិនអាចមានសេចក្តីសុខសុភមង្គល ឬសេចក្តីស្ងប់ឡើយ នៅលើផែនដីនេះ ដរាបណានៅមានភាពក្រីក្រ ភាព-ទុរ្ភិក្ស ភាពអយុត្តិធម៌ ការប្រើអំណាចជិះជាន់ ការរើសអើងជាតិសាសន៍ វិយោគកម្មខាងជាតិសាសន៍ អស្ថេរភាព និងអំពើអសីលធម៌សង្គម សេចក្តីភ័យខ្លាច ភាពមិនស្មោះត្រង់ និងសេចក្តីសង្ស័យ។ ការគោរពចំពោះខ្លួនឯង គឺមានសារសំខាន់ណាស់ ប្រៀបបីដូចជាអាហារអ៊ីចឹង ហើយក៏គ្មានសេចក្តីគោរពចំពោះខ្លួនឯងឡើយ ចំណោមបុគ្គលដែលមិនមានឱ-កាសសម្រេចបាននូវភាពរុងរឿងនៃមនុស្សជាតិរបស់ខ្លួន។

Religion, if it is true religion, must take the whole of man as its province and not merely certain aspects of his life. The good man, i.e., the man who follows his religion, knows that there can be no happiness or peace on earth as long as there is poverty and starvation, injustice and oppression, discriminative legislation, racial segregation, social disabilities and inequalities, corroding fear, mutual distrust and suspicion. Self-respect is as necessary to happiness as food, and there can be no self-respect among those

who do not have opportunity to achieve the full stature of their manhood.

## បញ្ហាពិភពលោក

WORLD PROBLEMS

សព្វថ្ងៃនេះ បញ្ហាដែលនៅចំពោះមុខមនុស្សជាតិ ហើយនិងគំរាមកំហែងគ្រប់រចនាសម្ព័ន្ធនៃមនុស្សជាតិ គឺបញ្ហាពិភពលោក និងមិនអាចបែងចែកថា នៅក្នុងតំបន់ភូមិសាស្ត្រនេះ ឬតំបន់ភូមិសាស្ត្រនោះឡើយ។ ដូច្នេះ ដំណោះស្រាយបញ្ហានេះ ក៏ត្រូវតែស្រាវជ្រាវរាវរកក្នុងពិភពលោកនេះដែរ។ រឿងនេះមានជាប់ពាក់ព័ន្ធនឹងទស្សនៈថ្មីនៃខ្សែស្រឡាយមនុស្សមិនមែនត្រឹមតែក្នុងគ្រួសារ និងផ្ទះ, រាជធានីរបស់យើង, ភូមិ និងប្រទេសរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងបរិបទនៃពិភពលោកទាំងមូល។ តម្រូវឱ្យមានការអប់រំបុរសស្ត្រី ទាក់ទិនក្នុងភាពអវិជ្ជាមាននៃសេចក្តីសោកសៅជាតិនិយម សាសន៍និយម ពណ៌សម្បុរ និងជំនឿ សាសនា បញ្ញានៃការយល់ដឹងពីបវេណីវប្បធម៌។ ប្រសិនបើ យើងពិតជាស្វែងរកសន្តិភាពមែនយើងត្រូវតែលះបង់ទាំងឡាយមានដូចជា ភាពមិនអត់ធ្មត់, ភាពក្រអើត-ក្រទម, និងអាកប្បកិរិយាចង្អៀតចង្អល់ ដែលមើលងាយដល់មនុស្សជាតិវប្បធម៌, សាសនា, និងមាគ៌ាជីវិតដែលផ្សេងពីមាគ៌ារបស់យើងឱ្យអស់។



The problems that today face mankind and threaten the very structure of humanity are world-problems and not isolated in this or that geographical area. Their solution, therefore, has to be sought it world terms. This involves new conceptions, on our part, of human relations, not only in the family and the home, our city, village and our country, but in the context of the world. There is the need to educate men and women in regard to the evil of sorrow, nationalism, racism, colour and creed and of the wisdom of cultural empathy. Intolerance, arrogance and bigotry which seek to deprecate and denigrate other peoples, other cultures, other religion , other ways of life different from our own – these must be eradicated, if we are to find peace.

## អតីតកាលកំណាច

SINISTER PAST

គេច្រើនសន្និដ្ឋានថា សាសនាមានរឿងអតីតកាលដ៏អាក្រក់ ត្រូវសងមកវិញ។ ជារឿយៗ បេសកកម្មរបស់សាសនា ចំពោះមនុស្សជាតិត្រូវបានដាក់ចូលទៅជាតម្រូវការនៃនយោបាយវិជ្ជាសាស្ត្រខេត្ត ឬនយោបាយជាតិ និងផែនការណ៍ដ៏កំណាចសម្រាប់ការពង្រីកអំណាច និងការច្បាំងដណ្តើមគ្នា។ កាលពីសម័យដើម សង្គ្រាមជាតិស្ទើរតែទាំងអស់ ក៏ជា

សង្គ្រាមសាសនាផងដែរ។ ជានិច្ចកាល សាសនាបានកប់ខ្លួននឹងវិធីបុណ្យ និង ជំនឿងាប់ក្រឡាផ្សេងៗ បញ្ហានៃអង្គការរដ្ឋ និងភាពមិនចេះភាន់-ច្រឡំគ្នានៃសៀវភៅ និងមនុស្ស។ ដូច្នេះ សាសនាបានដាក់ខ្លួនឱ្យទាបធ្វើជាគំរូ និងជាសច្ចាប្រណិធាន។ មានការស្ទាក់ស្ទើរណាស់ ក្នុងការធ្វើឱ្យមានការងាកថ្មីណាមួយ ប្រហារប្រឆាំងនឹងអំពើអយុត្តិធមិ, លាតត្រដាងអំពើអាត្មានិយម, ប្រើប្រាស់អំណាចរបស់ខ្លួន ញ៉ាំងសត្វស្វា និងខ្លាឱ្យស្លាប់ជាមួយយើង ហើយសត្វលា ជាសត្វស្លាប់វេទនាបំផុតចំណោមសត្វទាំងអស់។

It has been admitted that religion has, in many respects, a sinister past to redeem. Too frequently, its mission to mankind has been submitted to exigencies of provincial or national politics and nefarious schemes for aggrandizement and conquest. In earlier ages, most national wars were also religious wars. Too often, also, religion has buried itself with details of ritual and dogmas, questions of ministerial organization and the infallibility of books and persons. It thus narrowed itself down to priestcraft and sacraments. There has been great reluctance to make any new departure, to attack injustice, to expose selfishness, to use its power to make the ape and the tiger die within us, and the donkey, who dies hardest of all.



# ការបង្កើតអាណាចក្រ

## SECULARISATION

មនុស្សសម័យថ្មីនេះមានសិទ្ធិសាកសួរថា តើត្រូវយកសាសនាមកប្រើដូចម្តេច សម្រាប់យើងនាសម័យកាលនេះ? ពួកគេបានចោទថា សាសនា បានបម្រើតែគោលបំណងរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះទុកឱ្យវាស្លាប់ចុះ។ នេះហើយជាមូលហេតុចម្បងនៃការបង្កើតអាណាចក្រ ដែលសាសនាត្រូវតែប្រឈមមុខនៅគ្រប់ទីកន្លែង។ ដោយសារបញ្ហាទាំងឡាយដែលកើតពីការបង្កើតអាណាចក្រ គឺជារឿងសាមញ្ញ ឬមិនសាមញ្ញ សម្រាប់សាសនាពិភពលោកទាំងអស់ទៅហើយ ដូច្នេះក្នុងទីនេះ មិនចាំបាច់ត្រូវការត្រួតពិនិត្យយ៉ាងពិសេសនោះទេ។

Modern man has, therefore, the right to ask what use has religion for us of this age? They would argue that religion has served its purpose; let it, therefore, die. This is the main cause of secularization which religion everywhere has to face. Since the problems arising from secularization are more or less common to all the world religion, there is no need to examine them specifically here.

ទោះបីយ៉ាងណាក្តី ភាពក្លាហានបំផុតរបស់ពួកគេ គឺជាបញ្ហាដែលទាក់ទងនឹងភាពក្មេងខ្ចីនៃពិភពលោកនេះ ចំពោះបុគ្គលណាដែលមានការពិភាល់ច្រើន ក្នុងចំណោមជំនាន់ចាស់ ហើយជាចម្បងចំណោមមេដឹកនាំសាសនាផ្សេងៗ។ ការពិភាល់ទាំងឡាយនេះ ផ្តោតអារម្មណ៍ខ្លាំង នៅជុំវិញអំពើហិង្សាទូទៅ ចំណោមចលនាយុវវ័យយ៉ាងច្រើន និងការប្រើ-ប្រាស់ជាតិអាភៀន និងថ្នាំញៀន ដោយយុវជន និងយុវនារីមានចំនួនដ៏ច្រើន។ កត្តាទាំងពីរនេះហើយ ជានិមិត្តសញ្ញានៃជម្ងឺដ៏ធ្ងន់ធ្ងរ ក៏ដូចជាជម្ងឺទាំងឡាយផ្សេងទៀត ដែលច្បាស់ជាផលនៃហេតុបច្ច័យពិតនេះ។ វាជាហេតុបច្ច័យ ដែលយើងត្រូវតែស្រាវជ្រាវរកឱ្យឃើញ មុនពេលយើងអាចគិតពីឱសថ។

The gravest of them, however, are the problems connected with the youth of the world about whom there exist many misgivings among the older generation and chiefly among the leaders of the various religions. These misgivings centre mainly round the violence prevalent among many youth movements and the use of narcotics and drugs by large number of young men and women. Both these factors seem to be symptoms of a deep-rooted disease, which, like all other diseases, must be the result of certain causes. It is the causes that we must discover before we can think of remedies.



# ថ្នាក់វប្បធម៌

## STRATA OF CULTURE

ស្ទើរតែគ្រប់ប្រទេស នៅក្នុងពិភពលោកទំនើប មានចំណាត់ថ្នាក់នៃវប្បធម៌ដែលគួរឱ្យកត់សម្គាល់ចំនួនបីប្រការ។ ទីមួយវប្បធម៌ប្រពៃណី នៃសីលធម៌សាមញ្ញ អភិរក្សក្នុងទិដ្ឋភាពទូទៅ ដែលអាចត្រូវបានហៅថាវប្បធម៌ធម្មតា ដែលព្យាយាមថែរក្សានូវវប្បធម៌បុរាណទាំងឡាយ ដែលគេបានសាកល្បងក្នុងមណ្ឌលពិសោធន៍។ ទីពីរ គឺសង្គមដែលរៀបចំតាមបែបបច្ចេកវិទ្យាទំនើប ដែលមិនសុញ ព្យាយាមកែសម្រួលខ្លួនតាមការប្រែប្រួល ដែលកើតមានជុំវិញខ្លួន មួយអន្លើដោយភាពរហ័សរហួន។ ទីបីគឺអ្វីដែលគេហៅថា វប្បធម៌ចម្រុះ បានប្រតិស្ឋាននៅក្នុងចិត្តថ្មី ដោយហៅថា មនុស្សប្រឆាំងនឹងទម្លាប់សង្គម សក់របស់ពួកគេវែង រូបរាងកាយមិនស្អាតបាត ការសាកសួរពីជំនឿ និងគុណធម៌ ជាមួយទំនោររបស់គេខ្លាំងទៅនឹងតន្ត្រីកន្ទ្រាក់អារម្មណ៍ ចំណងកាមគុណមិនចេះស្កប់ស្កល់ ការប្រើ-ប្រាស់ជាតិអាភៀន និងថ្នាំញៀន មួយអន្លើដោយការស្រែកឡូឡាទៅនឹងបែបបទជីវិត វិលទៅរកធម្មជាតិវិញ នូវអ្វីដែលគេហៅថា សោភ័ណនិយមស្រើបស្រាល។

In almost every country in the modern world, there seem to be three, fairly distinguishable strata of culture. First there is the traditional culture of simple virtues, conservative in outlook, which might be called the culture of normalcy striving to maintain ancient values which have been tested in the crucible of experience. The second is the modern technologically organized society, liberal in outlook, trying to adapt itself to changes taking place around it, with almost breath-taking rapidity. The third is what has been called counter-culture, represented in the popular mind by so-called hippies, with their long hair, unkempt appearance, questioning the beliefs and values, with their penchant for rock-music, uninhibited sex indulgence in narcotics and drugs with noisy demonstrations turning to a communal or tribal life-style, going back to Nature in what they called 'sheer aestheticism'.

វប្បធម៌មិចម្រុះនេះជាទូទៅត្រូវមើលងាយ និងស្អប់ខ្ពើម ដោយវប្បធម៌ពីរផ្សេងទៀត។ ទោះជាយ៉ាងណា ក៏នៅមានបុគ្គលដែលបានធ្វើការសិក្សាយ៉ាងជិតនឹងវប្បធម៌មិចម្រុះ រក្សាថា រូបភាពសម័យថ្មីនេះ គឺមិនត្រូវ មិនស៊ីជម្រៅ សើៗ ហើយថា អាកប្បកិរិយាដែលមិនប្រែប្រួល គឺគ្រាន់តែជាអត្ថន័យនៃការប្រឆាំងនឹងសង្គមកើតឡើង ដែលពួកគេចាត់ទុកដូចជាជំរុញឱ្យធ្វើអ្វីមួយ ដោយសេចក្តីមិនចូលចិត្ត និងប្រយោជន៍ផ្ទាល់ខ្លួន។



This counter-culture group is generally looked upon with fear and disgust by the other two cultures. However, there are those, who, having made a close study of counter-culture, maintain that the popular image is wrong, shallow and superficial, and that the unorthodox behaviour is only a means of protest against established society which they regard as completely motivated by prejudice and self-interest.

## ខន្តី និង មុទិតា

## TOLERANCE AND SYMPATHY

ក្នុងពន្លឺនៃអ្វីដែលគេបានថែងរួចមកហើយ អ្វីដែលគួរជាឥរិយាបថរបស់សាសនា ចំពោះមនុស្សសម័យទំនើប ដែលរស់នៅគ្រប់ទីកន្លែង មានចំនួនធំ ឬ តូច។ ដោយពិតទៅ វាគួរតែជាអាកប្បកិរិយាល្អ សេចក្តីអត់ធ្មត់ និងសេចក្តីសន្តោសប្រណី ហើយជាពិសេស ការយល់ត្រូវ ភាពទន់ភ្លន់ និងការតម្រូវតាម។

In the light of what has thus been stated, what should be the attitude of religion to those of the modern age, who are to be found everywhere, in numbers large or small. Surely, it should be an attitude, tolerance and sympathy and above all, of understanding, flexibility and adaptation.

ចូរយើងកុំភ្លេចថា មេដឹកនាំសាសនាខ្លះ ជាអ្នកបដិវត្តខ្លួនពួកគេ។ ជាក់ស្តែង ព្រះសម្មាសម្ពុទ្ធ ជាជនឧទ្ទាមដ៏ខ្លាំងក្លាបំផុតក្នុងប្រវត្តិសាស្ត្រមនុស្ស ព្រះអង្គបានបដិសេធនូវការសន្និដ្ឋាន ចំពោះសាសនាណាមួយ ក្នុងសម័យកាលរបស់ព្រះអង្គ និងបានផ្តល់នូវភស្តុតាង តាមបែបសាសនា ការបង្ហាញផ្លូវថ្មីយ៉ាងច្បាស់លាស់មួយ។ ព្រះអង្គបានបដិសេធមិនទទួលយកសេចក្តីស្មោះត្រង់ ចំពោះវេទមន្ត ឬអំណាចនៃពួកបព្វជិត។ ព្រះអង្គបដិសេធនូវជំនឿខុស ដែលថា បញ្ហាមនុស្សត្រូវបានដោះស្រាយតាមវិធី-សម្ងាត់ និងមន្តគាថា។ ព្រះអង្គជាសត្រូវនៃប្រព័ន្ធវណ្ណនិយម ដែលជារចនាសម្ព័ន្ធនៃសង្គមឥណ្ឌាប្រកាន់យក។ ព្រះអង្គត្រូវគេសើចចំអក និងធ្វើទុក្ខបុកម្នេញ ហើយការប៉ុនប៉ងផ្សេងៗ ត្រូវបានគេធ្វើមកលើជីវិតរបស់ព្រះអង្គ។

Let us not forget that some of the leaders of religion have themselves been revolutionaries. The Buddha, for instance, was one of the greatest rebels in human history. He denied the assumptions on which religion in his day was based and gave religious quest an entirely new orientation. He refused to accept the sincerity of the Vedas or the power of the priesthood. He refuted the illusion that human problems could be solved with sacred ritual and incantations. He was a sworn enemy of the caste system on which the whole



structure of Indian Society rested. He was ridiculed and persecuted and several attempts were made on his life.

## លក្ខណដែលលេចឡើង
## SALIENT CHARACTERISTICS

អំឡុងពេល ២៥០០ ឆ្នាំនៃប្រវត្តិសាស្ត្ររបស់ខ្លួន ពុទ្ធសាសនាបានប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងជោគជ័យ ដែលបានកើតឡើងចំពោះខ្លួន។ ភាពរឹងមាំ និងសេចក្តីអត់ធ្មត់ជាលក្ខណៈដែលលេចឡើង។ វាមិនមានស្ថាប័នឋានានុក្រម និងគ្មានជំនឿតឹងរ៉ឹងដែរ។ ឥទ្ធិពលដែលមិនបណ្តាលឱ្យមានគ្រោះថ្នាក់របស់ខ្លួន ត្រូវបានពង្រីងតាមរយៈវប្បធម៌ និងទំនៀមទម្លាប់ ដែលបានសាបព្រោះក្នុងប្រទេសទាំងឡាយ ដែលបានសាយភាយដល់។ វាជាទ្រឹស្តីមួយសម្រាប់មនុស្សសម័យថ្មី និងមានឥទ្ធិពលដូចជានៅសម័យព្រះអង្គធរមានដែរ។ ពុទ្ធសាសនាមិនបានសន្យាថា ជម្ងឺដែលមនុស្សជាតិរងគ្រោះ អាចធ្វើឱ្យធូរស្រាល តាមមធ្យោបាយគ្រឹះនៃសង្គមទាំងមូលទេ។ ខណៈពេលបដិសេធនូវអំពើបាប ដែលមានក្នុងមនុស្សតាំងពីកំណើត ពុទ្ធសាសនាបញ្ជាក់ថា ការរួចចាកទុក្ខ គឺជាកិច្ចការងាររបស់បុគ្គលម្នាក់ៗ ដែលអាចសម្រេចបានតាមរយៈអំពើសីលធម៌ និងការ

អប់រំចិត្តប៉ុណ្ណោះ។ ពាក្យប្រៀនប្រដៅនេះត្រូវបានសង្ខេប ដោយព្រះពុទ្ធអង្គផ្ទាល់ ដូច្នេះថាៈ "ត្រូវវៀរចាការប្រព្រឹត្តិអំពើអាក្រក់, ត្រូវបំពេញតែអំពើកុសល និងត្រូវជម្រះចិត្តឱ្យស្អាតចាកគ្រឿងសៅហ្មងទាំងឡាយ នេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ"។

During the 2500 years of its history, Buddhism has successfully faced the challenges that confronted it. Resilience and tolerance have been among its salient characteristics. It has no hierarchical institutions and no rigid dogmas. Its benign influence on humanity is proved by the cultures and civilizations which have grown in countries into which it has spread. It has a message for modern man as potent as in the days of the Buddha. Buddhism does not promise that the ills from which humanity suffers can be alleviated in any fundamental way by some grand, overall organization of society. While denying any innate sinfulness in man , it declares that salvation is an individual affair and can be achieved only by virtuous conduct and mental culture. Its whole teaching has been summarized by the Buddha himself as:

"The avoidance of all evil: the accumulation of the good; the purification of one's mind –this is the message of the Buddhas."



# អាណានិគមនិយម

## COLONIALISM

កំឡុងពេល ៤ ឬ ៥ សតវត្សកន្លងទៅនេះ ពុទ្ធសាសនាបានរងគ្រោះដោយសារអាណានិគមនិយម។ ដោយសារសង្គ្រាមទាំងខាងក្នុង ទាំងខាងក្រៅនៃការព្យាយាមដោយចេតនា របស់សាសនិកនៃសាសនាទាំងឡាយធ្វើឱ្យចុះខ្សោយ និងផ្តួលរំលំវា។ ព្រះសង្ឃដែលបានរក្សានូវពាក្យទូន្មាននេះ ឱ្យមានជីវិត និងអ្នកដែលពេញចិត្តគាំទ្រនៃពួកអាណានិគម នៅក្នុងអំណាចនោះ បានធ្វើឱ្យបែកបាក់គ្នា ហើយបានធ្វើឱ្យធ្លាក់ចុះខ្សោយ ជាលទ្ធផលនៃឥទ្ធិពល ហួសពីការគ្រប់គ្រងរបស់ខ្លួន។

During the last four or five centuries, Buddhism has suffered from colonialism. By external and internal wars of the deliberate efforts of the followers of the religions to weaken and destroy it. The Saṅgha which has kept the teaching alive and which enjoyed the patronage of those in power has been disorganized and weakened as a result of forces beyond its control.

ប៉ុន្តែ នៅពេលមួយ ទិដ្ឋភាពនេះគឺមានពន្លឺឡើង។ សាមគ្គីភាពរបស់ពុទ្ធសាសនិកត្រូវបានចម្រើនទៅមុខ ដោយអង្គការ មានដូចជាសមាគមពុទ្ធសាសនាសាកល និងមហាសន្និបាតសង្ឃពិភពលោក ដែលបាននាំមក

នូវពុទ្ធសាសនាមហាយាន និងពុទ្ធសាសនាថេរវាទ ដើម្បីច្របាច់បញ្ចូលនូវកម្មវិធីជាធ្លុងមួយ ។ មានដំណោះស្រាយនៃរឿងអនក្ខរភាព និងភាពក្រីក្រក្នុងចំណោមពុទ្ធសាសនិកទាំងឡាយ បានទទួលជោគជ័យ ។ ព្រះសង្ឃត្រូវតែអប់រំប្រឡូកជាមួយតម្រូវការសង្គមទំនើប ។ ពុទ្ធសាសនាមិនមែនជាសាសនាព្រងើយកន្តើយ រឹងរូសឡើយ ។ ពុទ្ធសាសនាជាសាសនាដែលមានឥទ្ធិពលបំផុតលើពិភពលោក ។

But, the outlook is once more bright. Buddhist unity has been forged by such organization as the World Fellowship of Buddhists and the World Saṅgha Council which have brought together Mahayana and Theravada in order to follow a joint program of action. There is a great deal of illiteracy and poverty among Buddhist peoples to be overcome. The Saṅgha must be educated to meet modern needs. Buddhism has never been a passive, docile religion. It has been one of the greatest civilizing forces of the world.

"ចំពោះបុគ្គលអ្នកសង្កេត ដែលនៅជំពាក់ជំពិន ដូចជាយើងទាំងអស់គ្នាដែរនោះ ក្នុងភ័ព្វវាសនាធម្មតានៃមនុស្សជាតិ សូម្បីតែស្រមោលនៃពន្លឺក៏ស្វាគមន៍ផងដែរ ។ មនុស្សនឹងមើលពន្លឺដែលកំពុងភ្លឺភ្លិបភ្លែត១ ដោយ



មិនមានវិញ្ញាណ ប៉ុន្តែមិនមែនគ្មានមុទិតា និងមិនមែនគ្មានសង្ឃឹមនោះទេ ។

"For an observer who is implicated, as we all are, in the common destiny of mankind, even a gleam of light is welcome. He will watch the light's flickering without illusion, but not without sympathy and mot without hope."

ចប់ដោយបរិបូរណ៍នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៨

ម៉ោង ៨ ព្រឹក

**គណៈកម្មការត្រួតពិនិត្យ និងកែសម្រួល**

-ភិក្ខុ **សឿង វុឌ្ឍី** ថ្នាក់អនុបណ្ឌិត (B.Dh)

-ភិក្ខុ **ឈុំ ឆន** ថ្នាក់បរិញ្ញាបត្រ (B.Dh)

-ភិក្ខុ **អ៊ុំ សត្ថា** ថ្នាក់បរិញ្ញាបត្រ (B.Dh)

-ភិក្ខុ **មួន វិចិត្រ** ថ្នាក់បរិញ្ញាបត្រ (B.Dh)

-ភិក្ខុ **ព្រហ្ម សំណាង** ថ្នាក់បរិញ្ញាបត្រ (B.Dh)

-ភិក្ខុ **លាង សារ៉េយ** ថ្នាក់បរិញ្ញាបត្រ (B.Dh)

-លោក **ព្រុំ ស៊ីណា** ថ្នាក់បរិញ្ញាបត្រ (B.Dh)

**វាយកុំព្យូទ័រដោយ**

-ភិក្ខុ **ស៊ុយ សុវណ្ណ** ថ្នាក់បរិញ្ញាបត្រ (B.Dh)

**រចនាគ្របដោយ**

-ភិក្ខុ **ស៊ុយ សុវណ្ណ**

អាសយដ្ឋាន
E-mail: sovann4u@gmail.com